ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 08-May-2015, 15:55
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី២៧៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វែនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៉ង

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms. Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ឌេល លីសាក់ *(Mr.Dale LYSAK)*

លោក ស្រ៊ា រតនៈ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

លោកស្រី ទូច វរល័ក្ស

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោកស្រី ជេត វណ្ណលី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្ង សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក សុន អរុណ | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:១០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់នូវសេចក្តីសន្និដ្ឋានតបរបស់ភាគីម្ខាងៗចំពោះការដាក់ឯកសារគន្លឹះពាក់ព័ន្ធជាមួយនឹងអង្គហេតុសហករណ៍ និងត្រាំកក់ – សហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់។

កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ កត់សម្គាល់ផងដែរពីវត្តមានលោក លីវ សុវណ្ណា ដែលក្រុមមេធាវីការពារក្តី នួន ជា បានស្នើសុំឲ្យអង្គជំនុំជម្រះផ្តល់សិទ្ធិចូលរួមការពារក្តីនៅក្នុងសវនាការចំពោះមុខអង្គជំនុំជម្រះសាលាដំបូង សូមអរគុណលោកប្រធាន។

[០៩:០៣:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥ ដែលបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥។ ដោយមេធាវីការពារក្តីរបស់ខ្លួន

បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬសិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា ថ្ងៃនេះមានអាការៈឈឺចង្កេះរ៉ាំរ៉ៃ មានអារម្មណ៍វិលមុខពេលបន្ទាស់ទី និងបានផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតចូលរួមតាមដានកិច្ចដំណើរសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តចូលរួម និងតាមដានកិច្ចដំណើរសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយ ស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃដំណើរសវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៥:៤៧]

បាទ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះ ដោយអនុលោមតាមវិធាន២២(២)(ក) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះនឹងធ្វើកិច្ចនីតិវិធីមួយទៀត ឆ្លើយតបទៅនឹងសំណើសុំរបស់មេធាវីការពារក្ដី នួន ជា អង្គជំនុំជម្រះបានទទួលលិខិតមួយរបស់ក្រុមមេធាវីការពារក្ដី នួន ជា ដែលស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងផ្ដល់សិទ្ធិការពារក្ដីដល់ លីវ សុវណ្ណា ដែលជាទីប្រឹក្សាច្បាប់នៅក្នុងក្រុមមេធាវីការពារក្ដី នួន ជា។ លិខិតរបស់ក្រុមមេធាវការការពារក្ដី នួន ជា នឹងត្រូវបានដាក់ភ្ជាប់ជាមួយនឹងកំណត់ហេតុលាយ-លក្ខណ៍អក្សរនៃកិច្ចដំណើរការសវនាការថ្ងៃនេះ ផ្អែកតាមខ្លឹមសារនៃលិខិតដែលអង្គជំនុំជម្រះសាលាដំបូងបានទទួល។ អង្គជំនុំជម្រះយល់ឃើញថា លោក លីវ សុវណ្ណា មានគុណសម្បត្តិអាចឱ្យអង្គជំនុំជម្រះទទួលស្គាល់មេធាវីការពារក្ដីជនជាប់ចោទ នួន ជា នៅចំពោះមុខអង្គជំនុំជម្រះបាន។

ហេតុដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកមេធាវី សុន អរុណ ដែលជាមេធាវីជាតិការពារក្ដីលោក នួន ជា ឡើងធ្វើការស្នើសុំទទួលស្គាល់លោក លីវ សុវណ្ណា ជាមេធាវីការពារក្ដីឱ្យលោក នួន ជា

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ សូមអញ្ជើញលោក សុន អរុណ!

[០៩:០៧:០៤]

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។ ខ្ញុំ សុន អរុណ មេធាវីការពារលោក នួន ជា។ ថ្ងៃនេះ ខ្ញុំមានកិត្តិយសនឹងបង្ហាញខ្លួនលោក លីវ សុវណ្ណា ដែលជាមេធាវីមានតួនាទីជាទីប្រឹក្សាច្បាប់របស់ក្រុមលោក នួន ជា ហើយឥឡូវនេះលោក លីវ សុវណ្ណា បានមកអង្គុយចំពោះមុខតុលាការ។ សូមបង្ហាញខ្លួន បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី សុន អរុណ។

លោក លីវ សុវណ្ណា ពេលនេះ អង្គជំនុំជម្រះទទួលស្គាល់លោកជាមេធាវីការពារក្ដីឱ្យជនជាប់ចោទ នួន ជា ក្នុងសំណុំរឿង០០២ សម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ។ បាទ សូមអង្គុយចុះ!

ជាបន្តទៅនេះ អង្គជំនុំជម្រះប្រគល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនូវឱកាសធ្វើសេចក្ដីសន្និដ្ឋានតបទៅនឹងការដាក់បង្ហាញឯកសារគន្លឹះពាក់ព័ន្ធនឹងអង្គហេតុសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់របស់ក្រុមមេធាវីការពារក្ដី។ ហើយតំណាងសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលកន្លះថ្ងៃ។ សូមអញ្ជើញបាទ!

[០៩:០៨:៣៦]

**លោក ឌេល លីសាក់៖**

អរុណសួស្ដីលោកប្រធាន លោក លោកស្រីចៅក្រម មេធាវីការពារក្ដី សហការីទាំងអស់។ ខ្ញុំនឹងគិតថា អាចបញ្ចប់ការកត់សម្គាល់របស់ខ្ញុំនេះ នៅមុនពេលឈប់សម្រាក។ ដូច្នេះ យើងខ្ញុំយល់ឃើញថាយើងខ្ញុំអាចនឹងបញ្ចប់តែរយៈពេលកន្លះថ្ងៃ។ ខ្ញុំបានកត់សម្គាល់ឃើញនូវការបង្ហាញ គឺថាមានឯកសារ ១៣៨ឯកសារ ហើយឧបសម្ព័ន្ធ៨ និងឧបសម្ព័ន្ធរបស់ដែលរស់រានមានជីវិតមកស្រុកត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ ការបកប្រែជាភាសាអង់គ្លេសនៃឯកសារទាំងអស់នេះ សរុបទាំងអស់ប្រហែលជាមានចំនួន៧០០ទំព័រ ហើយលោក កូប៉េ ក៏បានលើកឡើងយ៉ាងត្រឹមត្រូវផងដែរ មានថាមាន

ឯកសារមួយចំនួនមាននៅក្នុងសំណុំរឿងហើយ ចេញពីឧបសម្ព័ន្ធហ្នឹង មានឯកសារមួយ ហើយមានឯកសារជាច្រើនទៀតក៏បានថតចម្លងដាក់ជាមួយគ្នានោះដែរ។ ដូច្នេះ ឯកសារនៅសេសសល់ពីស្រុកត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ប្រហែលជាមានលើសពី ១៣៨ឯកសារទៅទៀត អាចមានកំណត់ហេតុជាបុគ្គលនោះជាង ៣០០ឯកសារឯណោះ។ ជាការគួរឱ្យចង់ដឹងផងដែរ ដែលថាមេធាវីការពារក្តីអាចបង្ហាញនូវឯកសារណាមួយដែលមានសារប្រយោជន៍ដល់សំណុំរឿងរបស់ខ្លួន នៅក្នុងចំណោមឯកសារដែលនៅសេសសល់ជាង១០០ពីស្រុកគំរូមួយនេះ។ ទីកន្លែងនេះគឺថាត្រូវបាន នួន ជា, ខៀវ សំផន និងគណៈមជ្ឈិមបានទទួលស្គាល់ស្រុកគំរូចំនួនបីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ មេធាវីការពារក្តី ខៀវ សំផន មិនអាចរកឯកសារណាមួយយកមកបង្ហាញបានទេនៅក្នុងចំណោមឯកសារដែលនៅសេសសល់ពីស្រុកត្រាំកក់នោះ។ ចំពោះហេតុផលនេះ ខ្ញុំនឹងពន្យល់អំពីកំណត់ត្រានៅសល់ពីស្រុកត្រាំកក់ដែលមេធាវីការពារក្តី នួន ជា បានបង្ហាញ ដើម្បីបង្ហាញនូវភស្តុតាង និងការសម្លាប់រង្គាលនៅក្នុងស្រុកគំរូមួយនេះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[០៩:១១:៣២]

លោកប្រធាន ឯកសារពីរប្រភេទដែលមេធាវីការពារក្តី នួន ជា បានបង្ហាញ គឺរៀបរាប់ថាជាឯកសារដែលបង្ហាញថាអ្នកទោសខ្លះគឺត្រូវបានគេយកទៅអប់រំកែប្រែនៅឃុំមុននឹងបញ្ជូនទៅក្រាំងតាចាន់ ហើយឯកសារខ្លះក៏បង្ហាញផងដែរថា ថ្នាក់ឃុំបានស្នើសុំមតិណែនាំពីអង្គការស្រុក ពាក់ព័ន្ធទៅនឹងអ្នកដែលត្រូវបានគេចាត់ទុកថាជាខ្មាំងនេះ។ នៅក្នុងសំណើរបស់យើងខ្ញុំ ឯកសារទាំងអស់នេះគឺថា មិនជួយទៅដល់មេធាវីការពារក្តីនោះទេ។ ឯកសារនេះបង្ហាញថា ក្បាលម៉ាស៊ីនប្រតិបត្តិការសន្តិសុខដែលត្រូវបានគេយល់ថាចំពោះអ្នកដែលចាប់ខ្លួនថាជាខ្មាំងត្រូវបញ្ជូនមកមន្ទីរអប់រំកែប្រែ ហើយត្រូវប្រឈមមុខទៅនឹងការសួរចម្លើយ ការធ្វើទារុណកម្ម និងការសម្លាប់ចោល។ វាជាដំណើរការមួយដែលមានលក្ខណៈជាប្រព័ន្ធ តាំងពីថ្នាក់ក្រោមទៅដល់ឋានានុក្រមថ្នាក់ខ្ពស់នៅក្នុងការបញ្ជានេះ។ ឧទាហរណ៍ដែលមេធាវីការពារក្តី នួន ជា លើកឡើងគឺ អ្នកដែលបានទៅចូលខ្លួននៅក្រាំងតាចាន់ជាចុងក្រោយដែលមិនបានទទួលនូវការអប់រំកែប្រែ នូវការកែប្រែទេ គឺថាទៅប្រឈមមុខនឹងសេចក្តីស្លាប់តែម្តង។ តើឯកសារទាំងនេះជួយមេធាវីការពារក្តីដោយរបៀបណា ដែលថាមនុស្សទាំងនេះគឺថាត្រូវបានសម្លាប់ចោល ឬក៏ផ្ញើបញ្ជូនទៅអប់រំកែប្រែ មុននឹងចូលទៅដល់គុកក្រាំងតាចាន់ជាចុងក្រោយនោះ។

[០៩:១៣:២២]

ចំណុចទីពីរ នៅលើឯកសារទាំងនេះ គឺថា ឧទាហរណ៍ស្ទើរតែទាំងអស់ដែលលោក កូប៉េ បាន លើកឡើងពាក់ព័ន្ធទៅនឹងឯកសារនេះ គឺមនុស្សដែលគេចោទប្រកាន់ថាបានប្រព្រឹត្តអ្វីមួយខុស ដោយលួចចំណីអាហារយកទៅហូប។ យើងនិយាយអំពីមនុស្សដែលគាត់មានការអត់ឃ្លានដែលឡើងបេះដូងដែលលួចជីកដំឡូងយកទៅហូប។ ហើយឯកសារដែលមេធាវីការពារក្តីបង្ហាញគឺថា មនុស្សទាំងអស់នោះជួនកាលត្រូវប្រឈមមុខទៅនឹងការអប់រំកែប្រែដោយមេកង ឬក៏ដោយថ្នាក់ឃុំ យើងមិនដឹងថាការអប់រំនេះយ៉ាងម៉េចទេ ក៏ប៉ុន្តែប្រហែលជាត្រូវ -- ជាការព្រមាន ឬប្រដៅថាចំពោះអ្នកដែលអត់ឃ្លានទាំងនោះ ហើយឯកសារទាំងនេះក៏បង្ហាញផងដែរថា អ្នកដែលមិនរាងចាលគឺថា គាត់នៅស្រែកឃ្លាននៅតែបន្តលួចទេ គឺថាជោគវាសនារបស់អ្នកទាំងនោះជាចុងក្រោយ គឺទៅនៅជាប់ចុងក្រោយនៅក្រាំងតាចាន់។ ទទ្បីករណ៍របស់មេធាវីការពារក្តីគឺ សុំទោស ពួកប្រជាជនថ្មី សុំទោស គឺថាយើងមិនអាច ឲ្យអ្នកឯងហូបគ្រប់គ្រាន់បានទេ គឺថាអ្នកឯងត្រូវប្រឈមមុខនឹងការអប់រំកែប្រែ ហើយអ្នកឯងខកខានមិនបានធ្វើតាមយើងណែនាំ អ្នកឯងត្រូវបញ្ជូនទៅក្រាំងតាចាន់ ប្រឈមមុខនឹងសេចក្តីស្លាប់ ដោយសារតែការលួចចំណីអាហារហូប។

មេធាវីការពារក្តីបានរៀបរាប់ឯកសារទាំងអស់នេះថា វាបង្ហាញនូវទិដ្ឋភាពនៅក្នុងស្រុកត្រាំកក់ដែលនៅក្នុងនោះគឺថា មិនបាន -- មេធាវីការពារក្តីមិនដែលបានលើកឡើងអំពីពាក្យថា "សាហាវព្រៃផ្សៃ" យ៉ាងណានោះទេ។ នេះគឺអ្វីដែលមេធាវីការពារក្តីគឺថា បានលើកឡើងយកមកនិយាយ។ ខ្ញុំសូមជូននូវឧទាហរណ៍មួយចំនួនទាក់ទងទៅនឹងឯកសារដែលមេធាវីការពារក្តីបង្ហាញជូនអង្គជំនុំជម្រះ ពាក់ព័ន្ធទៅនឹងការអប់រំកែប្រែ ហើយនិងការសុំមតិណែនាំពីអង្គការ។

[០៩:១៥:៤៥]

ខ្ញុំនឹងផ្តល់នូវឧទាហរណ៍ពីរនៃឯកសារដែលមេធាវីការពារក្តីបានបង្ហាញ ទី១គឺឯកសារ E3/2424 ERN ភាសាខ្មែរ 00270755 ដល់ 56, អង់គ្លេស 00322220 និងបារាំង 00612219។ ឯកសារនេះគឺឯកសារ E3/2424។

លោក លោកស្រីចៅក្រមនេះគឺជាឯកសារមកពីឃុំអង្គតាសោម ផ្ញើជូនសមមិត្តបងស្រុក១០៥ សមមិត្តបងស្រុក១០៥ សូមផ្តល់មតិពាក់ព័ន្ធទៅនឹងមនុស្សម្នាក់ឈ្មោះ គង់ វ៉េត។ ខ្ញុំសូមអានផ្នែកដំបូង និងផ្នែកចុងក្រោយនៃឯកសារនេះ កថាខណ្ឌទី១នៃឯកសារនេះ "ជូនបងជាទីគោរព៖ នេះគឺជាអំពីសកម្មភាពរបស់អាខ្មាំងឈ្មោះ គង់ វ៉េត ដែលវាលួចជាច្រើន នេះគឺថាអានេះពូកែលួចណាស់ វាត្រូវបានក្រុម

កង និងអង្គប្រជុំសមូហភាពទិតៀនហើយ ក៏ប៉ុន្តែវាមិនរាងចាលទេ។ ក្រោយពីត្រូវបានអប់រំ ដោយប្រើវិធីក្តៅរួចមក វាបានសារភាពថា --" ហើយកថាខណ្ឌចុងក្រោយនៃរបាយការណ៍នេះគឺបាននិយាយដូចតទៅ សូមដកស្រង់៖ "ហេតុដូច្នេះ ខ្ញុំសូមជូនខ្មាំងទាំងបីនាក់ខាងលើជាមួយនឹងរបាយការណ៍ភ្ជាប់ជាមួយ ដើម្បីឲ្យសួរចម្លើយបន្តទៅទៀត ហើយដើម្បីឲ្យស្វែងរកខ្មាំងបង្កប់មកលាក់ខ្លួននៅក្នុងភូមិឃុំរបស់យើង និងចាត់វិធានការបន្ថែមទៀត ដើម្បីសម្រេចបានទៅតាមគោលការណ៍របស់បក្ស"។

ឯកសារនេះ ក៏ត្រូវបានលើកឡើងម្តងទៀតដើម្បីបង្ហាញឲ្យឃើញថា ជីវិតរស់នៅៗស្រុកត្រាំកក់ គឺមិនមែនវាមានភាពសាហាវព្រៃផ្សៃជាទូទៅទេ ហើយសម្រាប់ឯកសារនេះ មេធាវីការពារក្តីបានបង្ហាញជូនអង្គជំនុំជម្រះរាយការណ៍អំពីមនុស្សម្នាក់ដែលត្រូវបានអប់រំដោយប្រើវិធីក្តៅនៅក្នុងឃុំ ឬនៅក្នុងកងមួយនេះ។

[០៩:១៨:៥១]

មេធាវីការពារក្តីក៏បានបង្ហាញឯកសារដែលបង្ហាញថា អ្នកដែលលួចចំណីអាហារត្រូវបានចាត់ទុកថាជា"ខ្មាំង" ហើយត្រូវប្រឈមមុខទៅនឹងការសួរចម្លើយដើម្បីជីកកកាយរកខ្សែរយៈរបស់ខ្មាំងទាំងនេះ។ ហើយដោយយោងតាមបញ្ហានេះ សូមដកស្រង់៖ "យោងតាមគោលការណ៍របស់បក្ស សម្រេចតាមទិសរបស់បក្ស យើងដឹងហើយថាលោក គង់ វ៉ែត នេះគឺថាត្រូវទៅជាប់នៅគុកក្រាំងតាចាន់ យោងទៅតាមរបាយការណ៍មួយនេះ។ ហើយនៅក្នុងសៀវភៅកក់ត្រាក៏មានឈ្មោះរបស់គាត់ផងដែរ"។ នៅក្នុងសៀវភៅកំណត់ត្រានៅគុកក្រាំងតាចាន់ចំនួនពីរមានឈ្មោះរបស់គាត់។ បញ្ជីអ្នកទោសមួយនៅគុកក្រាំងតា -- សៀវភៅកត់ត្រាំងតាចាន់គឺ E3/4083ៗ, ត្រង់ ERN ជាភាសាខ្មែរ 00068026, អង់គ្លេស 00323949, ហើយបារាំង 00077856។ ឈ្មោះរបស់បុគ្គលនេះក៏បាននៅក្នុងបញ្ជីអ្នកទោស ហើយក៏មាននៅក្នុងសៀវភៅកត់ត្រាគុកក្រាំងតាចាន់ គឺឯកសារ E3/4092 គឺមាន ERN ជាភាសាអង់គ្លេស 00834828 ខ្ញុំនឹងបង្ហាញកំណត់ត្រានៅក្នុងការសួរចម្លើយនេះ ដែលថា គង់ វ៉ែត ហ្នឹងបានលួចដំឡូងប្រាំដង លួចដូងបីដង។

ឧទាហរណ៍ទី២ របស់ខ្ញុំទាក់ទងទៅនឹងឯកសារដែលមេធាវីការពារក្តី បានបង្ហាញនៅក្នុងផ្នែកនៃការបង្ហាញឯកសារនេះ គឺជាឧទាហរណ៍មួយដែលកម្មាភិបាលបក្ស សូមដកស្រង់គឺ "ប្រុងប្រយ័ត្ន" បញ្ចប់ការដកស្រង់។ ហើយនៅក្នុងបន្តនេះគាត់បានបង្ហាញនូវឯកសារ E3/2453ៗ, ERN ភាសាខ្មែរ 00270784 ដល់ 785, អង់គ្លេស 00388586, បារាំង 00611775។ យើងខ្ញុំសូមអានឯកសារនេះ

ជូនអង្គជំនុំជម្រះទាំងស្រុងតែម្តង នេះគឺឯកសារចុះថ្ងៃទី១៨ តុលា របាយការណ៍ ១៨តុលា មកពីឃុំញ៉ៀងញ៉ង ផ្ញើជូនបក្សស្រុកដែលសរសេរដូចតទៅ "ទី១ សភាពការណ៍ខ្មាំង ដែលលេចចេញនៅមូលដ្ឋានដូចតទៅ ឈ្មោះ ឡូ អេងទ្រី, ស្លូស ទី, យុន យាន និង បាង ណន។ អ្នកទាំងបួននាក់នេះ ដែលមានសកម្មភាពច្រើនបានរាយការណ៍ជូនបក្សលើកមុនហើយ ហើយយើងខ្ញុំបានតាមដានជាបន្តបន្ទាប់ ព្រោះវាបានប្រជុំគ្នានៅទំនប់ជ្រៃទង ហើយឥឡូវនេះគេមានកិច្ចប្រជុំមួយទៀត ហើយវាក៏បានទៅទាក់ទងគ្នានៅម្តុំឃុំសំឡាញ ស្រុក១០៦ ព្រោះវានៅទីនោះមានព្រំប្រទល់ជាប់គ្នា ហើយបានជួបប្រជុំគ្នា។ មិនមានបុគ្គល ថាតើវាមានផែនការកម្ទេចយើង កម្ទេចបដិវត្តន៍យើងហើយ។ ខ្ញុំមិនដឹងវា -- បើតាមបុគ្គល ខ្ញុំវិភាគគឺវាមានផែនការកម្ទេចបដិវត្តន៍យើង ឧទាហរណ៍ដូចជាវាឲ្យ -- វាភ្លួរគោក្របីទាំងថ្ងៃ ហើយវាមិនសូវយកចិត្តទុកដាក់ធ្វើការងារទេ។ សកម្មភាពរបស់អ្នកទាំងបួននាក់នេះ គឺថាសកម្មភាពក្រឡេចក្រឡុច អំពីសកម្មភាពដូចតទៅៈ ឡូ អេងទ្រី ធ្វើពីឡុតអាកាសចរណ៍, ២) យុន យានលេខាធិការឃ្លាំងសម្ភារៈសឹក ទី៣ គឺជាមេប៉េអឹម និងទី៤ បាង ណន ទាហានពលទោ។ អ្នកទាំងបួននាក់ហ្នឹង គឺសូមជ្រាបជាព័ត៌មាន ហើយសូមឲ្យបក្សមេត្តាផ្តល់ព័ត៌មានឲ្យយើងខ្ញុំផង បើបក្សសម្រេចយ៉ាងណាៗនោះ"។ នេះគឺជារបាយការណ៍មកពីថ្នាក់ឃុំ។ តើសេចក្តីសម្រេចរបស់បក្សវាយ៉ាងម៉េចដែរពាក់ព័ន្ធទៅនឹងមនុស្សដែលគេសង្ស័យទាំងបួននាក់នេះ។ ហើយដែលនាក់ទាំងបួននាក់នេះ គឺថាបានមានចំណាយពេលវេលាជួបជុំគ្នា។ នៅក្នុងឯកសារនេះដដែលក៏មានការឆ្លើយតបទៅវិញផងដែរ នៅថ្ងៃដដែលនោះ តាសាន បានសរសេរថាៈ "ជម្រាបជូនមក បងគិត ខ្ញុំសម្រេចឲ្យចាប់អ្នកទាំងបួននេះហើយ"។

លោក លោកស្រីចៅក្រម នេះគឺជាគំនិតរបស់ នួន ជា ដែលត្រូវថាត្រូវមានការប្រុងប្រយ័ត្នការចាប់ខ្លួនប្រជាជនដោយគ្រាន់តែមានការសង្ស័យ ហើយអាចមិនមែនជាខ្មាំងទេ។ នេះគឺជាអាយុជីវិត ឬក៏ជីវិតនៃការរស់នៅក្នុងស្រុកត្រាំកក់។

[០៩:២៥:៥៧]

ឯកសារដែលខ្ញុំតាមលើកឡើងអម្បាញ់មិញ គឺយោងទៅលើការវិភាគរបស់មេឃុំដែលថាអ្នកទាំងនេះអាចមានផែនការកម្ទេចបដិវត្តន៍។ ឥឡូវខ្ញុំសូមលើកឡើងទៅលើឯកសារនេះយ៉ាងសង្ខេបទេ។ នៅក្នុងសំណើរបស់យើងខ្ញុំដែលបានលើកឡើង ដែលបានលើកបង្ហាញឡើងដោយ នួន ជា គឺឯកសារដែលបង្ហាញដោយចង់សង្កត់អត្ថន័យខុសគ្នារវាងពាក្យថា "កម្ទេច"។ ហើយគ្រប់ប្រទេសនៅទាំងអស់នៅក្នុងពិភពលោកខ្ញុំយល់ឃើញថា មានពាក្យដែលអាចមានអត្ថន័យខុសគ្នាទៅតាមបរិបទផ្សេងគ្នា។

ជាភាសាអង់គ្លេស បើសិនណាជាថាខ្ញុំត្រូវសម្លាប់អ្នកណាម្នាក់ មានត្រង់ន័យអ៊ីចឹងតែម្តង ប៉ុន្តែពាក្យថា "សម្លាប់" ក៏គេអាចប្រើក្នុងន័យផ្សេងបាន។ អ្នកខ្លះនិយាយថា "មានអ្នកខ្លះកំពុងតែសម្លាប់សុបិនរបស់ខ្ញុំដែលខ្ញុំចង់ក្លាយជានាយករដ្ឋមន្ត្រីហើយ" ឧទាហរណ៍យ៉ាងដូច្នេះ។ អ៊ីចឹងពាក្យថា "*ស្មាស*" – ពាក្យ "កម្ទេច" ដូចជា "កម្ទេចសហករណ៍ កម្ទេចបដិវត្តន៍" មានន័យមួយផ្សេង ក៏ប៉ុន្តែវាក៏មានន័យផ្សេងដែរ នៅពេលដែលនិយាយ "កម្ទេចបុគ្គលណាម្នាក់ ឬក៏កម្ទេចអ្នកទោស" វាមានន័យមួយផ្សេង។ នៅពេលខ្មែរក្រហមនិយាយថា "កម្ទេចប្រជាជន ឬក៏កម្ទេចអ្នកទោស" គឺសម្លាប់គេចោលហើយ។ ជាការពិតហើយពាក្យ "*ស្មាស*" – ពាក្យ "កម្ទេច" នេះវាអាចមានអត្ថន័យផ្សេងទៅតាមបរិបទមួយផ្សេង។

[០៩:២៧:៤៣]

ប្រភេទឯកសារមួយផ្សេងទៀតដែលខ្ញុំនឹងលើកយកមកបង្ហាញឲ្យបានលឿននោះ គឺថាមេធាវីការពារក្តី នួន ជា បានធ្វើការបង្ហាញទៅលើឯកសារដែលបង្ហាញអំពីការសួរចម្លើយដោយប្រើប្រាស់វិធីក្តៅ។ ខ្ញុំសូមលើកឡើងពីរចំណុចពាក់ព័ន្ធទៅនឹងឯកសារនេះ។ មិនមានមូលដ្ឋានណាសម្រាប់មេធាវីការពារក្តីដើម្បីអាចអះអាងថា ការប្រើប្រាស់ ការធ្វើទារុណកម្មត្រូវតែចងក្រងជាឯកសារគ្រប់ករណីទាំងអស់។ មិនមានភស្តុតាងបង្ហាញអំពីការអនុវត្តបែបនេះ ក៏មានវិធានបែបនេះនោះទេ ដោយសារតែបញ្ហានេះឯង គឺថាវាមិនសមស្របទេដែលមេធាវីការពារក្តីប្រើប្រាស់វិធីក្តៅត្រូវមាននៅក្នុងសៀវភៅកត់ត្រានៅក្នុងគុកនោះ។ យើងត្រូវតែយោងទៅលើចម្លើយរបស់អ្នកទោស ចម្លើយរបស់កម្មាភិបាលដើម្បីឲ្យយល់ដឹងអំពីដំណើរការធ្វើទារុណកម្មនៅគុកក្រាំងតាចាន់។ យោបល់ទី២ មេធាវីការពារក្តីនៅក្នុងការបង្ហាញរបស់ខ្លួន គឺថាមើលរំលងចំពោះការប្រើប្រាស់វិធីក្តៅក្នុងការសួរចម្លើយ។ មិនមែនមានតែនៅក្នុងកំណត់ត្រារបស់បុគ្គលិកគុកនោះទេ នៅក្នុងឯកសាររបស់ខ្ញុំមាន ប៉ុន្តែខ្ញុំមិនលើកឡើងដដែលៗ គ្រាន់តែបង្ហាញថាឯកសារមួយចំនួនកម្មាភិបាលថ្នាក់ស្រុកៗ គឺថ្នាក់ឃុំ ថ្នាក់ស្រុកបាននិយាយគ្នាអំពីការប្រើប្រាស់វិធីក្តៅនេះ។ នេះគឺជាភស្តុតាងដ៏រឹងមាំហើយ ដោយវាបង្ហាញថាការប្រើប្រាស់ការសួរចម្លើយដោយប្រើវិធីក្តៅ ការធ្វើទារុណកម្មត្រូវបានគេដឹងជាទូទៅ និងត្រូវបានអនុញ្ញាតឲ្យថ្នាក់ដឹកនាំស្រុកត្រាំកក់។

[០៩:៣០:០៧]

បញ្ហាមួយទៀតដែលមេធាវីការពារក្តី នួន ជា បានលើកឡើងនៅក្នុងពេលខ្លួនបង្ហាញឯកសារ គឺទឡ្ហីករណ៍ដែលនិយាយថា ដោយសារថាយើងមិនមានឯកសារពណ៌ -- ឯកសារដើមពណ៌។ ដូច្នេះ

សក្ខីកម្មរបស់ ពេជ្រ ជឹម ដែលថាត្រូវបានប្រើប្រាស់ប៊ិកក្រហមដើម្បីបញ្ជាថាត្រូវកម្ទេចអ្នកទោសណាៗនោះ។ ខ្ញុំសូមបង្ហាញថា ពេជ្រ ជឹម បាននិយាយអំពីការអនុវត្តជាក់ស្ដែងនៅក្នុង -- ដោយលេខាតំបន់របស់គាត់ឈ្មោះ សោម។ គាត់ធ្វើជាលេខាតំបន់រហូតដល់ឆ្នាំ៧៦ ដូចដែលលោក លោកស្រីចៅក្រមបានជ្រាបហើយ ឯកសារនៅសេសសល់ពីក្រាំងតាចាន់ និងពីស្រុកត្រាំកក់ គឺគ្រាន់តែជាគំរូ ឬឧទាហរណ៍គំរូមួយផ្នែកនៃប្រតិបត្តិការមន្ទីរសន្តិសុខនេះតែប៉ុណ្ណោះ។ ហើយឯកសារភាគច្រើនពីឆ្នាំ១៩៧៩ និង១៩៨០ មិនមានឯកសារពីឆ្នាំ១៩៧៥ទេ វាមានកំណត់ត្រានៅសេសសល់ពីឆ្នាំ១៩៧៦តិចតួច ប៉ុន្តែឯកសារដ៏ច្រើនគឺត្រូវបានរកឃើញទាក់ទងទៅនឹងអំឡុងពេល ក្រោយពេលលេខាតំបន់ឈ្មោះ សោម នេះបានបញ្ចប់ទៅ ដូច្នេះបញ្ហាដែលលោក កូប៉េ លើកឡើងគឺជាបញ្ហាមួយបែប*អាកាដឺមិច* យើងមិនមានកំណត់ត្រា យើងមិនមានឧទាហរណ៍ណានៅសេសសល់នៅពេលដែល តាសោម ឬប្រធានតំបន់បានប្រើប្រាស់ដែលវិធីដែល ពេជ្រ ជឹម បានរៀបរាប់ឡើងថា កាលគេប្រើប៊ិកក្រហមហ្នឹង គឺចារប៊ិកក្រហមគឺឱ្យសម្លាប់អ្នកទោសហ្នឹងហើយ ប៉ុន្តែចូរកុំភ្លេចថាហេតុយ៉ាងម៉េចបានជាយើងមិនមានកំណត់ត្រាទាំងអស់ពីស្រុកត្រាំកក់ និងពីគុកក្រាំងតាចាន់ ឬក៏ពីកន្លែងផ្សេងទៀតនៃរបបកម្ពុជាប្រជាធិបតេយ្យ? នោះគឺដោយសារខ្មែរក្រហមមុនពេលរត់ចូលទៅ -- មុនពេលរត់ឡើងទៅភ្នំបានកម្ទេចចោលនូវឯកសារខ្លះៗ គឺឯកសារពាក់ព័ន្ធទៅនឹងអំពើសម្លាប់រង្គាលដែលពួកគេបានប្រព្រឹត្ត។

[០៩:៣២:៤៥]

ឥឡូវនេះ ខ្ញុំសូមចូលទៅបញ្ហាឯកសារដែលត្រូវបានចោទប្រកាន់ថាជាឯកសារក្លែងក្លាយ ក្លែងបន្លំ។ លោក លោកស្រីចៅក្រម ខ្ញុំសូមចាប់ផ្ដើមឡើងដោយបញ្ជាក់ថាការខកខានរបស់ខ្ញុំក្នុងការបង្ហាញនូវឯកសារដុំកំភួនណាមួយដើម្បីជួយទៅដល់មេធាវីការពារក្ដីនោះគឺថា ដោយបែបនេះ មេធាវីការពារក្ដីត្រូវតែនិយាយថាខ្លួនមិនធ្វើអ្វីដែលខ្លួនមិនត្រូវធ្វើនោះទេ នេះគឺជាបញ្ហាពាក់ព័ន្ធទៅនឹងភាពអាចទទួលយកបាននៃឯកសារ។ យើងមានសវនាការពីរឆ្នាំកន្លងមកហើយ ដែលថាភាពអាចទទួលយកបាននៃឯកសារត្រូវបានពិភាក្សាល្អិតល្អន់ ពិភាក្សា និងសម្រេចយ៉ាងល្អិតល្អន់។ បញ្ហា -- ចំណុចនេះវាហាក់ដូចជាយឺតបន្តិច ក៏ប៉ុន្តែគាត់បានចោទប្រកាន់ថាវាមានឯកសារក្លែងបន្លំបែបនេះ។ លោក កូប៉េ បានលើកឡើងឯកសារពីរដែលមានអក្សរសរសេរដោយដៃ ហើយក៏បានចូលទៅធ្វើសេចក្ដីសន្និដ្ឋានថាហេតុដូច្នេះឯកសារទាំងនេះគឺជាឯកសារក្លែងបន្លំ យើងបានស្ដាប់សក្ខីកម្មដែលថាស្រុក ឃុំ កម្មាភិបាលថ្នាក់ស្រុក ថ្នាក់ឃុំ គឺមិនមែនជាអ្នករៀនសូត្រចេះដឹងខ្ពង់ខ្ពស់នោះទេ ប៉ុន្តែតួនាទីរបស់ថ្នាក់ដឹកនាំ គឺថាជាអ្នកជួយ

ដែលជាអ្នកសរសេរឯកសារជំនួសឲ្យពួកគេ ហើយកម្មាភិបាលដែលចេះដឹងសរសេរជំនួសពួកគេ រួច ហើយបានទើបថ្នាក់ដឹកនាំនោះជាអ្នកស៊ីញ៉េ។ ដូច្នេះ វាមានអក្សរសរសេរដោយដៃពីរនៅក្នុងឯកសារទាំងនេះ ហើយមានឯកសារជាច្រើនបែបនេះមិនមែនមានន័យថាមានមនុស្សពីរនាក់ទេដែលពាក់ព័ន្ធទៅនឹងការរៀបចំឯកសារនេះ គឺអាចមានជំនួយការជាអ្នកសរសេរ ហើយបើសិនណាជាមកពីគុកមក ពេលនោះគឺថ្នាក់ឃុំ និងថ្នាក់ស្រុកជាអ្នកស៊ីញ៉េ ជាអ្នកចុះហត្ថលេខា។ មិនមានមធ្យោបាយណាមួយ ឬក៏មិនមានហេតុផលណាមួយដែលអាចបង្ហាញថា ឯកសារនេះជាឯកសារក្លែងបន្លំបានទេ។ ការជំទាស់តវ៉ាមួយទៀត ឬក៏ឯកសារមួយផ្សេងទៀត ដែលមេធាវីការពារក្ដីលើកឡើងថា ក៏ជាឯកសារក្លែងបន្លំដែរ គឺត្រង់ទំព័រមួយ គឺ E3/4145ៗ, ត្រង់ERN ជាភាសាខ្មែរ 00068736ៗ។ ខ្ញុំសូមការអនុញ្ញាតដើម្បីបង្ហាញឯកសារមួយនោះនៅក្នុងពេលដែលខ្ញុំកំពុងតែធ្វើការបង្ហាញឯកសារនេះ។ សូមការអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[០៩:៣៦:១៦]

**លោក ឌេល លីសាក់៖**

សូមអរគុណ។ យើងខ្ញុំសូមបង្ហាញនូវស្លាយទី១នៅលើអេក្រង់កុំព្យូទ័រ។ នៅក្នុងស្លាយទី១នេះ យើងឃើញទំព័រទី១ទាំងស្រុង ឈ្មោះវាវែងណាស់ ប៉ុន្តែចំណងជើងនោះដាក់ថា "បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ១០៥"។ មេធាវី កូប៉េ បានលើកឡើងពីរចំណុច គឺថាឯកសារនេះ គឺជាឯកសារក្លែងបន្លំដោយសារគេប្រើពាក្យថា "អឹម១០៥ – មន្ទីរ១០៥"។ "*អឹម*" គឺជាពាក្យថា មន្ទីរម១០៥ គឺមន្ទីរ។ នេះគឺជាអក្សរកាត់ដែលខាងមន្ទីរអប់រំកែប្រែស្រុក១០៥ហ្នឹង គឺគេប្រើអ៊ីចឹង មិនមានអ្នកណាអាចថាមន្ទីរ -- បើដាក់ថា "មន្ទីរស្រុក១០៥" គឺមានន័យថាជាឯកសារក្លែងក្លាយនោះទេ។ វាមានការអះអាងជាទូទៅពាក់ព័ន្ធទៅនឹងចំណុចនេះ។ ហើយក្នុងពេលជាមួយគ្នាដែរ មេធាវីការពារក្ដីនិយាយថា បញ្ជីអ្នកទោសដែលសរសេរដៃនេះ គឺជាឯកសារក្លែងក្លាយហើយ ហើយគាត់ទទួលស្គាល់ថាឯកសារមួយផ្សេងទៀតនៅក្នុងឯកសារ E3/4145 ក៏មានបញ្ជីនេះដូចគ្នាដែរ គឺឯកសារពិតប្រាកដ។

[០៩:៣៨:១៣]

បើសិនណាមានធ្វើបែបនេះ បើមកខាងខ្ញុំ គេថាវាជាការផ្សំគំនិតមួយបែបភ្លើៗ ឆ្កួតៗហើយ បើ

ប៊ាានធ្វើឯកសារបែបនេះ ក្លែងបន្លំបែបនេះ។ ខ្ញុំសូមពន្យល់ថាហេតុម៉េចបានវាយ៉ាងដូច្នេះ។ ទទ្បីករណ៏ទី២ ដែលមេធាវីការពារក្ដីលើកឡើងថាឯកសារនេះ ត្រូវតែជាឯកសារក្លែងបន្លំ ដោយសារតែវាមានការវាយខុសអក្ខរាវិរុទ្ធអីយ៉ាងដូច្នេះ ដូចជា ហ៊ុន គឹមសេង អីជាដើមយ៉ាងដូច្នេះ។ ដូចជា ហ៊ុន ណា ហៅ ណា ហើយបងស្រីរបស់គាត់ មាស សារ៉ាត់ ដែលយើងហៅនៅក្នុងពេលសវនាការ ហៅថា មាស សារ៉ាត់។ ដូច្នេះ ខ្ញុំសូមបង្ហាញស្លាយនេះជាថ្មីម្ដងទៀត ដើម្បីឲ្យអង្គជំនុំជម្រះផ្ដោតទៅលើផ្នែកមួយនៃឯកសារនេះ ដែលលោក កូប៉េ បាននិយាយថា វាមានពាក់ព័ន្ធព័ត៌មានដែលមិនត្រឹមត្រូវ ពាក់ព័ន្ធទៅនឹងមនុស្សទាំងពីរនាក់នេះ ហេតុដូច្នេះ ឯកសារនេះគឺជាឯកសារក្លែងបន្លំហើយ។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតស្លាយនេះម្ដងទៀតនៅលើអេក្រង់កុំព្យូទ័រ។

[០៩:៣៩:៣០]

នៅក្នុងស្លាយនេះ យើងបង្ហាញជូនទៅផ្នែកមួយនៃឯកសារ ដែលនិយាយអំពីពាក់ព័ន្ធទៅនឹងផ្នែកប្រវត្តិរបស់អ្នកទោស។ ម្ដាយរបស់ ហ៊ុន ញ៉ៅ, ម្ដាយរបស់ មាស សារ៉ាត។ ដូច្នេះ ខ្ញុំចូលត្រង់ បង្ហាញចំណុចនេះឡើងវិញម្ដងទៀត។ នៅពេលដែលយើងមើលទៅលើចំណុចនេះ លោក កូប៉េ បានធ្វើការអះអាង អត់ព្រមពិនិត្យ អត់បានពិនិត្យមើលឯកសារដើមជាភាសាខ្មែរទេ ដើម្បីពិនិត្យមើលថាតើឯកសារនេះបកប្រែទៅជាភាសាអង់គ្លេសយ៉ាងម៉េច។ បើយើងមើលឯកសារដើម ព័ត៌មានជាប់ឈ្មោះនៅក្បែរឈ្មោះអ្នកទាំងពីរនេះ គឺត្រឹមត្រូវហើយ។ ឈ្មោះ ហ៊ុន ញ៉ៅ គឺគ្រាន់តែមានគេ។ រីឯ មាស សារ៉ាត់ វិញគឺថា ដាក់ថាគាត់មកពីស្រែគ្រូ ឃុំជាងទង។ ហើយនៅពេលបកប្រែឯកសារនេះ អ្នកបកប្រែដាក់បំពេញព័ត៌មានឲ្យ ឈ្មោះ ហ៊ុន ញ៉ៅ បំពេញបន្ថែមព័ត៌មាន ហើយដោយសារតែបញ្ហានេះ លោក កូប៉េ ក៏បានឈានដល់ការធ្វើសេចក្ដីសន្និដ្ឋាន ថាឯកសារនេះគឺជាឯកសារក្លែងក្លាយហើយ។ កាលដែលខ្ញុំ បង្ហាញឯកសារនេះជូនអង្គជំនុំជម្រះថា ហេតុម៉េចបានមានការផ្សំគំនិតធ្វើបែបនេះ គឺថានៅពេលយើងមើលទៅឯកសារដើមនេះ មិនមានស្អីដែលថាវាមានការក្លែងបន្លំនោះទេ។

[០៩:៤១:២០]

ខ្ញុំសូមបង្ហាញនូវប្រភេទឯកសារមួយប្រភេទទៀត ដែលមេធាវីការពារក្ដីលើកឡើងផងដែរថាអាចជាឯកសារក្លែងបន្លំ។ នេះគឺជាឯកសារសរសេរដោយដៃ គឺសរសេរដោយអតីតចៅហ្វាយស្រុកឈ្មោះ តាសាន។ ហើយជាថ្មីម្ដងទៀត លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញលើអេក្រង់កុំព្យូទ័រខ្ញុំមានស្លាយមួយ ខ្ញុំ -- ក្នុងស្លាយនេះ គឺខ្ញុំដាក់កំណត់ត្រាសរសេរដោយដៃដោយ តាសាន ចំនួនបួន។

01096377



ហើយប្រសិនជាយើងមើលទៅលើហ្នឹង នេះគឺជាឯកសារបួនដែលឯកសារទាំងអស់ហ្នឹងមានឈ្មោះ តាសាន។ ខ្ញុំអាចជម្រាបជូនអង្គជំនុំជម្រះបានថា ឯកសារមួយក្នុងចំណោមឯកសារទាំងនេះ ដែល លោក កូប៉េ លើកឡើងថាជាឯកសារក្លែងបន្លំ ឯកសារមួយ ឬក៏ពីរក្នុងចំនួនទាំងបួននេះគឺថា សាន បាន ទទួលស្គាល់ថាជាអក្សររបស់គាត់ហើយ។ ហើយខ្ញុំជំទាស់តវ៉ាឲ្យពិចារណាមើល៍ បើលោកវិញលោក ថាមួយណាក្លែងក្លាយ ខ្ញុំមើលឯកសារទាំងបួននេះដូចគ្នាបេះបិតតែម្តង។ ហើយបើយើងពិនិត្យមើល ឯកសារនេះជាថ្មីម្តងទៀត សូមអនុញ្ញាតបង្ហាញម្តងទៀត។

[០៩:៤៣:០០]

មានចំណុចមួយដែលខ្ញុំចង់ឲ្យមានការផ្តោតការយកចិត្តទុកដាក់ គឺពីចំណុច គឺចំណុចសំខាន់ គឺ តាសាន គាត់ប្រើខទានសញ្ញា អូសមួយ ហើយចុចមក។ នៅក្នុងអក្សរសរសេរដោយដៃរបស់គាត់ គាត់ ទម្លាប់អ៊ីចឹង។ ខ្ញុំដូចជាវង្វេងដែរ ថាហេតុអីបានមេធាវីការពារក្តីនិយាយថា វាត្រូវតែមានយថាភាព-- មានការបញ្ជាក់យថាភាពទៅលើឯកសារទាំងអស់នេះ ពីព្រោះមានអ្នកណាម្នាក់បន្លំឯកសារនេះហើយ។ តាសាន អត់មានបាននិយាយថារបៀបនេះទេ។ បើយើងពិនិត្យមើលសក្ខីកម្មរបស់ខ្ញុំ ក៏អត់មានដែល និយាយថា ឯកសារហ្នឹងគឺឯកសារក្លែងបន្លំទេ គ្រាន់តែគាត់ថាឯកសារខ្លះគឺវាមើលទៅដូចជាខុសអក្សរ របស់គាត់តែប៉ុណ្ណឹង។ ឯកសារ -- គាត់និយាយថា ឯកសារដែលចេញមកពីថ្នាក់ស្រុក អាចជំនួយការ របស់គាត់ជួយសរសេរ។ តើគាត់អាចចាំអក្សរដៃនេះបានទេ ជាង៣០ឆ្នាំមកហើយ? អាចមិនចាំបាន ទេ។ ដើម្បីបញ្ជាក់ថាវាជាឯកសារក្លែងបន្លំ គឺការដែលគាត់ថាដូច្នេះ ប៉ុន្តែថាអត់មានមូលដ្ឋាន។ ឯកសារ នេះបានទទួលយកដាក់នៅក្នុងសំណុំរឿង ហើយយើងបានពិភាក្សាដេញដោលវាវួចមកហើយ ដើម្បីជៀស ផុតអំពីការចោទប្រកាន់ថា មានការឃុកឃិតបន្លំឯកសារនេះ។

[០៩:៤៥:១២]

ឯកសារចុងក្រោយដែលមេធាវីការពារក្តីបានលើកឡើងនៅក្នុងប្រភេទឯកសារដដែល គឺឯកសារ E3/4083។ នេះគឺសៀវភៅកត់ត្រាមួយក្បាលមកពីក្រាំងតាចាន់ ជាសៀវភៅដែលមានសរសេរបញ្ជី អ្នកទោសនៅទីហ្នឹង មិនមែនជាបញ្ជីសួរចម្លើយទេ តែបញ្ជីឈ្មោះអ្នកទោស។ ជម្រាបដោយត្រង់ ខ្ញុំមិន យល់ថាហេតុម៉េចមានការជំទាស់តវ៉ាថា ឯកសារនេះជាឯកសារក្លែងក្លាយ។ ខ្ញុំពិតជាបានកត់ត្រានូវ ចំណុចដែលលោក កូប៉េ បានលើកឡើងថាមានការយោងទៅលើឯកសារហ្នឹង ដែលយោងថាអ្នកទោស ត្រូវបានសម្លាប់នៅថ្ងៃទី០៨ មករា ១៩៧៩។ ខ្ញុំមិនដឹងថានេះវាជាកំហុសអ្វីណាមួយ ឬក៏ដោយសារគុក

ក្រាំងតាចាន់ជាគុកដាច់ស្រយាល ពេលហ្នឹងក៏រត់គេចខ្លួនអត់ទាន់ មានន័យថាអត់ដឹងថាត្រូវគេចខ្លួនទៅមុនហ្នឹងទេ បែរជាត្រូវគេច រត់ភៀសខ្លួននៅថ្ងៃទី០៨ មករា ៧៩ ទៅវិញ។ ប្រហែលជាអ៊ីចឹងក៏ខ្ញុំមិនដឹងដែរ។ វាមានសេចក្ដីសន្និដ្ឋានដែលអាចនិយាយថាបាននៅស-២១នោះ ថាតើ -- ក៏មិនបានទទួលឯកសារនេះពីគុកក្រាំងតាចាន់ដែរ ដោយសារតែខ្លួនត្រូវតែរត់ប្រាសអាយុដើម្បីរត់ឡើងទៅលើភ្នំ។ ប្រហែលនៅចងចាំថា មានឯកសារនៅសេសសល់ពីស-២១ គឺ ឌុច គាត់អត់បានទទួលការបង្គាប់បញ្ជាពីដើមថា ឲ្យរត់គេចខ្លួនឲ្យលឿន ឲ្យបានលឿននោះទេនៅពេលដែលៗត្រូវរត់គេចខ្លួនឡើងភ្នំនោះ។ ដូច្នេះ មានការលើកឡើងចំពោះពាក្យថា ថ្ងៃ០៨ មករា ១៩៧៩ គឺចង់បញ្ជាក់ថាមានអ្នកណាម្នាក់ចូលខ្លួននៅក្នុងថ្ងៃហ្នឹងមកដល់ចាប់ផ្ដើមរៀបចំឯកសារក្លែងបន្លំ។ ការយោង តើការយោងបែបហ្នឹងមានន័យថាម៉េច? តើមាន -- នៅថ្ងៃទី០៨ មករា ១៩៧៩ នៅតែមានកម្មាភិបាលគុកនៅទីហ្នឹងនៅឡើយឬ? ហើយក៏សូមអរគុណព្រះជាម្ចាស់ដែរ ដែលថាឯកសារទាំងអស់នោះសំណាងណាស់មិនត្រូវបានគេបំផ្លាញចោលទាំងស្រុង។

[០៩:៤៧:៥៧]

ការជំទាស់តវ៉ាៗគ្មានភស្តុតាងអ្វីបង្ហាញសោះនេះ គឺមិនអាចទទួលយកបានទេ។ យើងខ្ញុំបានជំទាស់តវ៉ាលើចំណុចនេះហើយ។ យើងខ្ញុំសូមលើកឡើងថាភស្តុតាងដែលយើងបានស្ដាប់ប៉ុន្មានខែកន្លងមកនេះ គឺថាវាលើសពីវិមតិសង្ស័យហើយពាក់ព័ន្ធទៅនឹងយថាភាពនៃឯកសារទាំងអស់នេះ។

ហើយក្រោយមកក៏យើងទៅជាជួបបញ្ហានៅពេល ដែលយើងបង្ហាញឯកសារទៅសួរសាក្សីថាតើសាក្សីផ្ដល់ចម្លើយមកវាស៊ីចង្វាក់គ្នាទៅនឹងឯកសារទាំងអស់នេះដែរឬក៏អត់។ ប៉ុន្តែយើងបានធ្វើបែបនេះក្នុងមូលហេតុមួយដែលសំខាន់គឺដើម្បីបង្ហាញឲ្យឃើញថាៗ ឯកសារទាំងអស់នេះ គឺពិតជាអាចគួរឲ្យជឿជាក់បាននិងទទួលយកបាន។

អ្នកទោសដែលគាត់បានអញ្ជើញមកនេះ គាត់ជាសាច់ញាតិរបស់ មាស សុខា យើងបានរកឃើញឯកសារយោងទៅនឹងសៀវភៅកត់ត្រាមួយនេះ នៅពេលដែលមានឈ្មោះអ្នកទោស ឬក៏មេឃុំ គឺឆ្លើយមក យើងឃើញថាទាំងអ្នកទោស ទាំងមេឃុំហ្នឹងគឺថាឆ្លើយមក គឺទាំងមេឃុំ ទាំងមេស្រុក ឆ្លើយតបទៅគឺវាស៊ីចង្វាក់គ្នាទៅនឹងមនុស្សដែលគេបានកំណត់អត្តសញ្ញាណនៅក្នុងសៀវភៅនោះ។ ហើយពីមួយពេលទៅមួយពេល យើងហៅថាការជាប់ទាក់ទងគ្នារវាងឯកសារមួយទៅឯកសារមួយ ដែលថាមនុស្សដែលគេនិយាយនៅក្នុងរបាយការណ៍ថ្នាក់ឃុំ ហើយយើងក៏ទៅឃើញឈ្មោះដដែល ដែលគេបញ្ជូនមកពីថ្នាក់ឃុំហ្នឹងក៏នៅក្នុងមន្ទីរសន្តិសុខនុ៎ងដែរ។

ខ្ញុំយល់ឃើញថា ខ្ញុំមិនមានពេលដែលត្រូវបង្ហាញ ERN ជាភាសាអង់គ្លេសទាំងបីផ្នែកបាននោះទេ។ ការដែលខ្ញុំលើកឡើងហ្នឹងគឺនឹងបង្ហាញឲ្យឃើញថា ឯកសារទាំងអស់នេះគឺជាឯកសារដែលមានយថាភាព។ គឺជាឯកសារដែលអាចឲ្យជឿជាក់បានហើយ។ ខ្ញុំគ្រាន់តែសុំជម្រាបអង្គជំនុំជម្រះថា ឯកសារនេះគឺជាឯកសារពិតជាសល់ពីរបបកម្ពុជាប្រជាធិបតេយ្យ។ ឯកសារទាំងនេះបង្ហាញថាតើជីវិភាពរបស់នៅរបស់ប្រជាជនវាយ៉ាងម៉េចនៅស្រុកនោះ។ ហើយនៅពេលដែលមកដល់ស-២១វិញ គឺឯកសារទាំងអស់នេះបង្ហាញថាតើជីវិតរស់នៅវាមានលក្ខណៈបែបណាសម្រាប់ប្រជាជនធម្មតា សម្រាប់ប្រជាជនមូលដ្ឋាន ប្រជាជនថ្មី ដែលគេត្រូវបានគេរកឃើញនៅក្នុងស្រុកមួយនេះ។

[០៩:៥០:៤៥]

មានប្រធានបន្ថែមមួយចំនួនទៀតដែលមេធាវីការពារក្ដីលើកឡើង ខ្ញុំសូមលើកបង្ហាញ។ ការលើកឡើងនេះខ្លីៗទេ។ មេធាវីការពារក្ដីបង្ហាញនូវឯកសារមួយប្រភេទ ដែលគេចាត់ទុកថាជាគោលការណ៍ណែនាំមកពីបក្ស និយាយអំពីឥរិយាបថដែលអាចទទួលយកបាន។ ប៉ុន្តែ អ្វីដែលខ្ញុំអាចផ្ដល់បន្ថែមបាននោះ គឺឯកសារ E3/216។ នេះគឺកំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ នៅថ្ងៃទី៤ ខែសីហា ១៩៧៥។ នៅពេលលោក កូប៉េ បង្ហាញឯកសារហ្នឹង គាត់អានសម្រង់មួយដែលសម្រង់នេះ -- សូមដកស្រង់៖ “យើងចង់និយាយអំពីប្រជាជនមូលដ្ឋាននិងប្រជាជនថ្មីភាគច្រើនដែលល្អ”។ អ្វីដែលគាត់ភ្លេចលើកយកមកនិយាយ ត្រង់ឃ្លាមួយគឺនៅខាងមុខហ្នឹង ដែលនិយាយថា “បញ្ហាទាំងអស់គឺមិនបញ្ហាទេជាមួយប្រជាជនមូលដ្ឋាន ក៏ប៉ុន្តែប្រុងប្រយ័ត្នចំពោះប្រជាជនថ្មី ពីព្រោះវាមានបញ្ហាមិនល្អទេជាមួយពួកប្រជាជនថ្មី ពីព្រោះពួកអាប្រជាជនថ្មី គឺអាចមិនចេះនៅជាមួយយើងបានទេ បើទោះបីជាយើងឲ្យហូបពីរពេលក្នុងមួយថ្ងៃក៏ដោយ” ហើយក៏គេមាននិយាយកថាខណ្ឌមួយចំនួននៅក្នុងកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នេះ គឺថាមានធាតុផ្សំ មានសមាសធាតុមិនល្អនៅក្នុងចំណោមប្រជាជនរាប់រយ រាប់ពាន់នាក់នេះ។ ហើយមេធាវី កូប៉េ មិនបាននិយាយថាបញ្ជីនៃកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ត្រង់ចំណុចលេខ២ហ្នឹងសរសេរថា “ប្រើឧបករណ៍មធ្យោបាយចម្រុះគ្នា ដើម្បីតាមដាន ជាពិសេសនៅតាមព្រំដែន រៀបចំផែនការ ថាតើគេប្រើគិញប៉ុន្មានក្នុងមួយខែ។ គ្រប់ប្រភេទគិញទាំងអស់ត្រូវបានគេប្រើប្រាស់ ដូច--” គេ -- មិនដឹងថាតើឯកសារយោង ឬក៏សំអាងរបស់មេធាវីការពារក្ដី ឬក៏អ្វីដែលខ្ញុំបង្ហាញនេះ វាពាក់ព័ន្ធ

ដោយផ្ទាល់ទៅនឹងស្រុកត្រាំកក់ ឬក៏អត់ទេ។ ការដែលខ្ញុំឆ្លើយ ធ្វើការឆ្លើយតបនេះ គឺវាគ្រាន់តែជាឧទាហរណ៍ដែលបក្សបានបង្កើតគោលការណ៍ ដែលថាឥរិយាបថណាខ្លះដែលអាចទទួលយកបាន

ឥរិយាបថរបស់ប្រជាជនប្រភេទណាខ្លះមិនអាចទទួលយកបាន។ បើយើងមើលទៅលើឯកសារនេះ គឺឯកសារនេះបង្ហាញយ៉ាងច្បាស់ហើយថាតើគណៈអចិន្ត្រៃយ៍បានគិតយ៉ាងម៉េច សម្រេចថាយ៉ាងម៉េចនូវអ្វីដែលអាចទទួលយកបាននោះ។

[០៩:៥៣:៥០]

ហើយជាចុងក្រោយ លោក លោកស្រីចៅក្រម ខ្ញុំសូមផ្តល់មតិ ទៅលើផ្នែកចុងក្រោយនៃការបង្ហាញឯកសារនេះ។ មេធាវីការពារក្តី នួន ជា បានបង្ហាញឯកសារមួយចំនួនជូនទៅដល់អង្គជំនុំជម្រះមានខ្សែវីដេអូ ទៅលើប្រធានបទស្តីពីការប្រព្រឹត្តទៅលើខ្មែរក្រោម និងពុទ្ធសាសនិកជន។ ហើយនៅក្នុងការបង្ហាញបែបនេះ ខ្ញុំកត់សម្គាល់ឃើញថា គាត់បានប្រើប្រាស់ការឃោសនាអប់រំរបស់ខ្មែរក្រហម គាត់បានប្រើពាក្យថា ការផ្សព្វផ្សាយដោយវិទ្យុរបស់ខ្មែរក្រហម ដែលរៀបរាប់ថា -- ដោយនិយាយអំពីដំណើរទស្សនកិច្ចរបស់ភ្ញៀវបរទេស គឺមានកិច្ចប្រជុំមួយថា កិច្ចប្រជុំរបស់ជនភៀសខ្លួនខ្មែរក្រហម ហើយក៏បង្ហាញនូវខ្សែភាពយន្តឃោសនារបស់ខ្មែរក្រហម មានឃើញ ប៉ុល ពត, នួន ជា ចូលរួមនៅក្នុងវគ្គឃោសនាអប់រំនេះ។ ខ្ញុំសូមបង្ហាញដោយសង្ខេបទៅលើចំណុចមួយនេះ។

លោក កូប៉េ គាត់បានសួរអង្គជំនុំជម្រះ -- បំភ្លេចអ្វីដែលកើតមានឡើងចំពោះពួកគេ ហើយត្រូវបើកខួរក្បាលឲ្យទូលាយទាំងអស់គ្នា។ ហើយអ្វីដែលគាត់ព្យាយាម គឺថាដាក់ព័ត៌មានមក គឺគាត់វាស្មាក់ស្មើរក្នុងការប្រើប្រាស់ការឃោសនារបស់ខ្មែរក្រហម។ ខ្ញុំសូមលើកឡើងជូនអង្គជំនុំជម្រះថា អ្វីដែលលោក កូប៉េ ថាឲ្យយើងទាំងអស់គ្នាទុកមួយអន្លើទៅចំពោះបញ្ហានេះ ហើយយើងគិតអំពីបញ្ហាណាដែលវាមានសមហេតុសមផលនោះ។ ខ្ញុំសូមអរគុណអង្គជំនុំជម្រះច្រើន ដែលអនុញ្ញាតឲ្យខ្ញុំនៅពេលវេលាដើម្បីធ្វើការកត់សម្គាល់ឆ្លើយតបទៅការបង្ហាញឯកសាររបស់មេធាវីការពារក្តី។ ខ្ញុំអស់ហើយលោកប្រធាន។

[០៩:៥៦:០២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើម-បណ្តឹងរដ្ឋប្បវេណី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ដោយសារតែលោក ខេល លីសាក់ គាត់បាននិយាយតាំងពីដើមរួច

មកហើយ យើងមិនមានមតិយោបល់អ្វីទៅលើការបង្ហាញឯកសាររបស់លោក នួន ជា ទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ដូច្នេះ អង្គជំនុំជម្រះផ្តល់វេទិកាបន្តទៅជូន ទៅលោកក្រុមមេធាវីការពារក្តីលោក នួន ជា!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សម្រាបសួរភាគីទាំងអស់។ យើងនឹងចាប់ផ្តើមបង្ហាញការជំទាស់របស់យើងទៅនឹងការបង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា។ យើងជំទាស់ទៅនឹងឯកសារជាច្រើនដែលបានបង្ហាញជូនកន្លងមក។ យើងនឹងព្យាយាមលើកឡើងនូវចំណុចពាក់ព័ន្ធជាក់លាក់ទៅនឹងអ្វីដែលពួកគាត់បង្ហាញ។ ចំណុចទី១ គឺនិយាយអំពីលក្ខខណ្ឌនៅក្នុងសហករណ៍នានា។ ឯកសារទី១ ដែលយើងចង់ជំទាស់នោះគឺ ឯកសាររបស់ ប៉ែន យៀរនិន ដែលមានចំណងជើង “របប ប៉ុល ពត” គឺឯកសារ E3/1593 ដែលជាប្រភពបន្ទាប់បន្សំ។ ក្រៅពីឯកសារនេះ សហព្រះរាជអាជ្ញាបានផ្តោតយ៉ាងខ្លាំងទៅលើប្រភពបន្ទាប់បន្សំពីរ ទី១គឺរបាយការណ៍របស់ ហង់រី ឡូកា ដែលមានចំណងជើងថា “ស្រុកត្រាំកក់នៅក្នុងកណ្តាប់ដៃខ្មែរក្រហម” គឺឯកសារលេខ D313/1.2.16 និងឯកសារជាសៀវភៅរបស់លោក អៀ ម៉េងទ្រី ដែលមានចំណងជើងថា “ខ្សែចង្វាក់នៃភាពភ័យខ្លាច” គឺឯកសារលេខ E3/2120។ ដូច្នេះលោកប្រធាន ខ្ញុំនឹងចាប់ផ្តើមមតិយោបល់ទូទៅពាក់ព័ន្ធទៅនឹងសៀវភៅទាំងអស់នេះ ហើយបន្ទាប់មកទៀតខ្ញុំនឹងនិយាយអំពីឯកសារទាំងនេះឡើងវិញ ដោយដាច់ដោយឡែកពីគ្នា។

[០៩:៥៨:៥២]

ប្រសិនបើយើងសិក្សាអំពីបញ្ជីសាក្សីរបស់ព្រះរាជអាជ្ញាសម្រាប់សវនាការនេះ យើងឃើញថា ហង់រី ឡូកា ស្ថិតនៅក្នុងបញ្ជីអ្នកជំនាញនិងសាក្សីដែលបានស្នើ។ ប៉ែន យៀរនិន គាត់មានស្ថិតនៅក្នុងបញ្ជីបម្រុង ហើយ អៀ ម៉េងទ្រី ក៏អត់មានស្ថិតនៅក្នុងបញ្ជីសាក្សីនេះទេ។ អ៊ីចឹងនៅក្នុងដំណាក់កាលនេះមិនមានអ្នកណាមួយក្នុងចំណោមអ្នកទាំងបីត្រូវបានកោះហៅនោះទេ។ នៅក្នុងពេលបង្ហាញឯកសារសហព្រះរាជអាជ្ញាបានចំណាយពេលជាច្រើន ទោះបីជាមានពេលកំណត់ក៏ដោយ ដើម្បីបង្ហាញអំពីសេចក្តីសន្និដ្ឋានរបស់អ្នកនិពន្ធទាំងបីនាក់នេះ។ ចំណុចនេះបង្ហាញឲ្យឃើញថា សម្រាប់សហព្រះរាជអាជ្ញា ឯកសារទាំងអស់នេះគឺជាឯកសារសំខាន់បំផុតសម្រាប់ពួកគាត់។ ដោយសារតែមានសារៈសំខាន់នេះ ការជំទាស់របស់យើងហ្នឹង គឺថាឯកសារនេះមិនអាចយកមកធ្វើ -- មិនទុកចិត្តបានទេ ដោយសារ

តែ ឃៀវសំផន, ឡូកា និង អៀ ម៉េងទ្រី មិនមកបង្ហាញខ្លួននៅក្នុងតុលាការនេះ ដើម្បីបង្ហាញអំពីវិធីសាស្ត្ររបស់ខ្លួន ហើយដើម្បីឲ្យយើងអាចដឹងអំពីសេចក្តីសន្និដ្ឋានរបស់គាត់ និងអាចដឹងអំពីទស្សនៈរបស់ពួកគាត់ ជាពិសេសក្នុងករណីរបស់លោក ឃៀវសំផន ដែលគាត់ជឿថាជាអ្នកលម្អៀងទៅខាងម៉ាក្សនិយម។ បើសិនជាយើងមិនអាចស្តាប់អ្នកទាំងបីនេះ យើងគិតថាឯកសារទាំងអស់នេះ គឺមិនអាចទុកចិត្តបាន ហើយវាមិនមានតម្លៃអ្វី -- វាមានតម្លៃជាភស្តុតាងតិចតួចបំផុត។ យើងដឹងច្បាស់ថា ឃៀវសំផន គាត់មិនមានឆន្ទៈក្នុងការមកផ្តល់សក្ខីកម្មទេ។ ដូច្នេះ យើងត្រូវតែប្រុងប្រយ័ត្នក្នុងការផ្តល់តម្លៃទៅលើទស្សនៈរបស់គាត់ ប្រសិនបើយើងធ្វើបែបនេះនោះ ហើយយើងគិតថា ទោះបីជាមិនចាំបាច់ពិនិត្យមើលឃ្លាទាំងអស់ដែលលើកឡើងដោយសហព្រះរាជអាជ្ញាក៏ដោយ ក៏យើងគួរតែផ្តល់ឧទាហរណ៍ដែលបញ្ជាក់អំពីវិធីសាស្ត្ររបស់ ឃៀវសំផន ក្នុងការស៊ើបអង្កេត។

[១០:០០:៥៥]

ក្នុងឃ្លាមួយ ឃៀវសំផន គាត់បាននិយាយថា កង្វះអាហារូបត្ថម្ភហ្នឹង គឺថាមានការកើតឡើងយ៉ាងខ្លាំងនៅក្នុងឆ្នាំ៧៧-៧៨ នៅក្នុងភូមិភាគនិរតី គឺឯកសារ ERN ជាភាសាអង់គ្លេស 00678719, ជាភាសាខ្មែរគឺ 00638012, ជាភាសាបារាំងគឺ 00639223។ លោក ឃៀវសំផន គាត់បានបញ្ជាក់ថា សេចក្តីសន្និដ្ឋាននេះ គឺផ្អែកទៅលើស្ថិតិមិនពេញលេញ ហើយក៏ផ្អែកទៅលើរឿងរ៉ាវរបស់អ្នកដែលបានគេចចេញពីតំបន់នោះ។ ដូច្នេះ ឃៀវសំផន គាត់មិនបានផ្តល់ទម្ងន់គ្រប់គ្រាន់ទៅលើផលប៉ះពាល់នៃសង្គ្រាមដ៏យូរអង្វែងដែលកើតមាននៅមុនរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ យើងឃើញថា មានការបំផ្លិចបំផ្លាញដោយសារសង្គ្រាមស៊ីវិលដែលមានការធ្វើជាឯកសារត្រឹមត្រូវ ហើយលោក ឃៀវសំផន គាត់ដឹងពីបញ្ហានេះដែរ ហើយនៅក្នុងផ្នែកមួយនៃសៀវភៅរបស់គាត់ ឃៀវសំផន ក៏បានដកស្រង់យ៉ាងច្រើនអំពីរបាយការណ៍របស់ យូសេត ដែលនិយាយអំពីលក្ខខណ្ឌនៅកម្ពុជាដែលកើតមាននៅមុនពេលការជម្លៀសចេញពីទីក្រុងភ្នំពេញ។ ដូច ឃៀវសំផន គាត់បានកត់សម្គាល់អ៊ីចឹង, យូសេត បាននិយាយថា នៅពេលដែលអាមេរិកឈប់ផ្តល់ជំនួយស្រូវនៅក្នុងខែមេសា ឆ្នាំ១៩៧៥ កម្ពុជា គឺស្ថិតនៅក្នុងភាពអត់ឃ្លានយ៉ាងខ្លាំង ហើយជាប្រទេសដែលត្រូវតស៊ូដើម្បីរស់ ត្រដររស់។ ឯកសារអង់គ្លេសហ្នឹងគឺ 0067 8526, ERN ភាសាខ្មែរ 00637453, ERN ជាភាសាអង់គ្លេសគឺ 00638793។

លោកប្រធាន មុនពេលខ្ញុំចូលទៅដល់ឯកសារបន្ទាប់ទៀត ខ្ញុំចង់បញ្ជាក់ថាសហព្រះរាជអាជ្ញាគាត់ផ្តោតទៅលើឯកសាររបស់ ឃៀវសំផន ដើម្បីភ្ជាប់ទំនាក់ទំនងទៅនឹងការធ្វើបាបទៅលើខ្មែរក្រោម។

[១០:០៣:០៥]

ដូច្នេះ ជាប្រធានបទទី២ នៃការបង្ហាញរបស់សហព្រះរាជអាជ្ញា ដូចដែលខ្ញុំបាននិយាយនៅក្នុងសវនាការមុនរួចមកហើយ ខ្ញុំមិនត្រឡប់មកនិយាយអំពីចំណុចដដែលហ្នឹងទេ ក៏ប៉ុន្តែខ្ញុំចង់បញ្ជាក់ជាថ្មីម្តងទៀតថា យើងជំទាស់យ៉ាងខ្លាំងទៅនឹងការប៉ុនប៉ងរបស់សហព្រះរាជអាជ្ញា ក្នុងការបង្ហាញអំពីបទពិសោធន៍ខ្មែរក្រោមនៅក្នុងកម្ពុជាប្រជាធិបតេយ្យនៅក្នុងវិសាលភាពនៃសវនាការយើងនេះ ក្នុងឋានៈជាក្រុមគោលដៅជាក់លាក់។ ហើយពួកគាត់ សហព្រះរាជអាជ្ញាក៏មិនបានស្នើសុំឱ្យបញ្ចូលចំណុចនេះនៅក្នុងដីកាដំណោះស្រាយទេ។ យើងនឹងពិនិត្យមើលឡើងវិញនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងចំណុចនេះ។ នេះជាបញ្ហាសំខាន់ ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តចំពោះខ្មែរក្រោម។ បន្ទាប់មកទៀត បន្ទាប់ពីសៀវភៅរបស់ ប៉ែន យៀវនិន សហព្រះរាជអាជ្ញាបានបង្ហាញឯកសារបន្ថែមជាច្រើនពាក់ព័ន្ធទៅនឹងការប្រព្រឹត្តចំពោះខ្មែរក្រោម និងជនជាតិវៀតណាមនៅក្នុងស្រុកត្រាំកក់។

នៅពេលដែលយើងអំពីបទពិសោធន៍របស់ខ្មែរក្រោម ការជំទាស់ទូទៅរបស់យើង គឺត្រូវយកមកអនុវត្តដោយសារតែយើងមិនចង់និយាយដដែលៗពាក់ព័ន្ធទៅនឹងបញ្ជីឯកសារនេះ។ ឧទាហរណ៍ដូចជាឯកសារ E3/2435, E3/2049, E3/4082, E3/2281, E3/4083, E3/2438, E3/2262, E3/2048, E3/2428 និងE3/4084។ តើខ្ញុំត្រូវបន្ថយល្បឿន ឬក៏យ៉ាងម៉េចលោកប្រធាន? សូមអភ័យទោសផង។ យើងបានបញ្ជូនបទបង្ហាញរបស់យើងនេះទៅឱ្យអ្នកបកប្រែហើយ ក៏ប៉ុន្តែយើងនឹងព្យាយាមនិយាយឱ្យបានយឺតៗ។

[១០:០៥:១០]

លោកប្រធាន យើងមានការជំទាស់ជាក់លាក់ជាច្រើនពាក់ព័ន្ធទៅនឹងឯកសារដែលខ្ញុំទើបតែធ្វើបញ្ជីអម្បាញ់មិញនេះ ដូច្នេះខ្ញុំនឹងពិនិត្យមើលទៅលើឯកសារទាំងអស់ហ្នឹង។ ខ្ញុំចាប់ផ្តើមដោយឯកសារលេខ E3/2107។ សហព្រះរាជអាជ្ញារៀបរាប់ថាឯកសារនេះ គឺជាកំណត់ហេតុនៅក្រាំងតាចាន់។ ខ្ញុំមានការជំទាស់ពីរពាក់ព័ន្ធទៅហ្នឹងឯកសារនេះ។ ទី១ សហព្រះរាជអាជ្ញាយោងទៅលើឯកសារនេះដើម្បីដកស្រង់នូវឃ្លាមួយពាក់ព័ន្ធទៅនឹងមនុស្សម្នាក់ឈ្មោះ ឌុច សំហឿន។ ខ្ញុំសូមដកស្រង់ លោកប្រធាន "នៅចុងឆ្នាំ៧៥ នៅពេលដែលអង្គការបញ្ជូនយួនទៅប្រទេសរបស់ខ្លួនវិញ គាត់បានធ្វើសំណើមួយដើម្បីបញ្ជាក់ថាគាត់ចង់ទៅវៀតណាម ពីព្រោះថាប្រពន្ធរបស់គាត់ជាជនជាតិយួន ហើយគាត់ឮថានៅវៀតណាមគឺមានទ្រព្យសម្បត្តិផ្ទាល់ខ្លួន ហើយមានចាយលុយ ក៏ប៉ុន្តែអង្គការមិនអនុញ្ញាតឱ្យគាត់ទៅ

ទេ។ គឺERN ជាភាសាអង់គ្លេស 00290204, ជាភាសាខ្មែរ 00068048, ជាភាសាបារាំង 00655724 ទៅដល់ 25។ ឯកសារនេះហាក់ដូចជាកំណត់ត្រានៃការសួរចម្លើយអ្នកទោសម្នាក់ ហើយនិងចម្លើយសារភាពរបស់គាត់។ អ៊ីចឹងសហព្រះរាជអាជ្ញាផ្អែកទៅលើឯកសារនេះ មិនមែនត្រឹមតែដើម្បីកំណត់អត្តសញ្ញាណសាក្សី អ្នកទោសទេ គឺគាត់យកខ្លឹមសារមកប្រើទៀតផង អ៊ីចឹងហើយបានខ្ញុំជំទាស់ដូចតទៅ។ យើងមិនយល់ថាហេតុអ្វីបានជាចំណុចនេះមានការខុសគ្នាអំពីការដែលខ្ញុំព្យាយាមប្រើប្រាស់ចម្លើយសារភាពមកពីស-២១ នៅថ្ងៃអង្គារ។ ខ្ញុំគិតថាដូចជាអត់មានអីខុសគ្នាទេ សហព្រះរាជអាជ្ញាហើយនិងអង្គជំនុំជម្រះព្យាយាមបង្កើតស្តង់ដារពីរពាក់ព័ន្ធទៅនឹងការប្រើប្រាស់ចម្លើយសារភាព ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ហើយភាគីផ្សេងមិនអាចប្រើប្រាស់បាន។ វាជាបញ្ហាច្បាប់ដែលយើងបាននិយាយរួចហើយកាលពីថ្ងៃអង្គារ។ យើងអាចលើកឡើងថាតើភស្តុតាងដែលបានមកពីការធ្វើទារុណកម្មអាចត្រូវបានប្រើប្រាស់យ៉ាងម៉េចនៅក្នុងការជំនុំជម្រះនេះ។ ដូចយើងដឹងហើយថាយើងបានប្តឹងសាទុក្ខពាក់ព័ន្ធនឹងបញ្ហានេះហើយនៅក្នុងសំណុំរឿង០០២/០១។ ដូច្នេះ មិនមានការសង្ស័យទេថានៅក្នុងអំឡុងពេលសវនាការប្តឹងសាទុក្ខនេះ យើងនឹងពិភាក្សាវែងឆ្ងាយទៅលើចំណុចនេះនៅក្នុងតុលាការកំពូល។ ក៏ប៉ុន្តែខ្ញុំអាចបញ្ជាក់បានម្តងទៀតថា សហព្រះរាជអាជ្ញាបានកំណត់នូវទឡ្ហីករណ៍របស់យើងថាជាទឡ្ហីករណ៍មួយដែលជាការទន់ខ្សោយខាងផ្នែកសីលធម៌ ខាងផ្នែកផ្លូវចិត្ត។ ដូច្នេះ យើងឃើញហើយថាសហព្រះរាជអាជ្ញាគាត់ព្យាយាមប្រើប្រាស់នូវភស្តុតាងប្រភេទ នេះតាមផ្លូវដូចគ្នា។

[១០:០៨:៣៥]

ការជំទាស់ទី២ ដែលខ្ញុំចង់លើកឡើងពាក់ព័ន្ធនឹងឯកសារនេះដដែលគឺ E3/2107 គឺពាក់ព័ន្ធទៅនឹងការកំណត់លក្ខណៈទៅលើឯកសារនេះថាជាកំណត់ត្រាមកពីក្រាំងតាចាន់ ដែលកំណត់ដោយសហព្រះរាជអាជ្ញា។ ដូច្នេះ យើងមើលទៅគឺថា មិនឃើញថាចំណុចណាមួយដែលបញ្ជាក់ថា ឯកសារហ្នឹងមកពីក្រាំងតាចាន់ទេ។ ឯកសារហ្នឹងមិនបានបញ្ជាក់ថាមកពីអង្គតាសោម ឬក៏មកពីមន្ទីរសន្តិសុខស្រុកទេ។

លោកប្រធាន ឥឡូវនេះ ខ្ញុំចូលទៅឯកសារមួយទៀតគឺលេខ D157.7។ បើតាមសហព្រះរាជអាជ្ញា អង្គជំនុំជម្រះបានផ្តល់លេខ E3 រួចទៅហើយគឺ E3/5827 ខ្ញុំជំទាស់ដដែលដូចជាការជំទាស់របស់ខ្ញុំទៅលើឯកសារលេខ E3/2107 អ៊ីចឹង។ ជាថ្មីម្តងទៀត ឯកសារនេះគឺឯកសារដែលទទួលបានក្រោយពីការសួរចម្លើយអ្នកទោស និងចម្លើយសារភាពរបស់អ្នកទោស។ ដូច្នេះសហព្រះរាជអាជ្ញាគាត់

បានយោងទៅលើឯកសារនេះ ដោយប្រើប្រាស់នូវខ្លឹមសារនៃឯកសារចម្លើយសារភាព។ សហព្រះរាជអាជ្ញាបានយោងទៅលើឃ្លាមួយនៅក្នុងចម្លើយសារភាពដែលរៀបរាប់ដូចតទៅ ខ្ញុំសូមដកស្រង់ថា "តើនៅក្នុងខែមករា ឆ្នាំ១៩៧៦ អង្គការបានព័ទ្ធ ឡោមព័ទ្ធពួកយួន ហើយបញ្ជូនទៅវៀតណាមវិញយ៉ាងម៉េច? ហើយថាតើយួនបានទទួលគ្រួសារនៅភ្នំដិនហ្នឹងយ៉ាងម៉េច? ហើយ -- ដូច្នេះជាថ្មីម្តងទៀតយើងមិនយល់សោះថា តើវាខុសគ្នាយ៉ាងម៉េច នៅទីនេះគឺថាមានការប្រើប្រាស់នូវស្តង់ដារពីរខុសគ្នាហើយ។

[១០:១០:៣៣]

ឥឡូវនេះលោកប្រធាន ខ្ញុំសូមបង្ហាញការជំទាស់ជាក់លាក់របស់ខ្ញុំពាក់ព័ន្ធទៅនឹងឯកសារ E3/2049 និង E3/4082។ សហព្រះរាជអាជ្ញាបានដកស្រង់ផ្នែកមួយពាក់ព័ន្ធទៅនឹងការប្រព្រឹត្តចំពោះជនជាតិវៀតណាមនិងខ្មែរក្រោម ដែលយើងមើលទៅហាក់ដូចជាមានការធ្វើបញ្ជីគ្រួសារខ្មែរក្រោម។ ជាការជំទាស់ទៅលើទម្រង់ជាដំបូង សហព្រះរាជអាជ្ញាបានពន្យល់កាលពីថ្ងៃចន្ទថា ឯកសារទាំងពីរនេះហាក់ដូចជាផ្នែកពីរនៃបញ្ជីជាបន្តបន្ទាប់តែមួយ។ អ៊ីចឹងខ្ញុំសួរថា តើហេតុអីបានជាបញ្ជីតែមួយនេះត្រូវបានគេបែងចែកជាពីរឯកសារ ហើយមានលេខឯកសារពីរផ្សេងគ្នា។ អ៊ីចឹង តើវាកើតឡើងយ៉ាងម៉េច? ហើយអ្នកណាជាអ្នកទទួលខុសត្រូវលើចំណុចនេះ?

នេះគឺជាបញ្ហាដែលទាមទារឲ្យមានការយកចិត្តទុកដាក់ខ្ពស់មុននឹងយើងប្រើប្រាស់លើឯកសារនេះដើម្បីយកមកធ្វើជាភស្តុតាង។ ដូច្នេះហើយបានជាការជំទាស់របស់ខ្ញុំនៅទីនេះគឺថា យើងមិនមានច្បាប់ដើមនៃឯកសារនេះទេ ហើយឯកសារទាំង១៣៤ ដែលថាមកពីស្រុកត្រាំកក់ហ្នឹងក៏យើងមិនមានច្បាប់ដើមដែរ យើងចង់បានច្បាប់ដើមដើម្បីសិក្សាឲ្យប្រុងប្រយ័ត្ន យើងមិនអាចទទួលបានទេ ដូច្នេះយើងត្រូវតែផ្តល់តម្លៃជាភស្តុតាងតិចតួចបំផុតទៅលើឯកសារទាំងអស់នេះ។

[១០:១២:០៨]

លោកប្រធាន ខ្ញុំគិតថាពេលនេះប្រហែលជាពេលសមស្របសម្រាប់ការសម្រាកសិន។ ហើយបន្ទាប់មកទៀត ខ្ញុំនឹងចូលទៅចំណុចផ្សេងទៀតពាក់ព័ន្ធទៅនឹងសហព្រះរាជអាជ្ញាដែលគាត់បានលើកឡើងពាក់ព័ន្ធទៅលើស្ត្រីខ្មែរក្រោមម្នាក់ដែលប្តីគាត់ជាស័ក្តិ៣ លន់ នល់។ ឯកសារនេះគឺបញ្ជាក់ថាបុគ្គលនោះត្រូវបានកម្ទេចចោលទៅហើយនៅពេលដែលគាត់មកដល់។ គឺឯកសារលេខយោង គឺជាភាសាអង់គ្លេស 00290263, ជាភាសាខ្មែរ 00079101, ជាភាសាបារាំង 00774256។ មុនពេលឈប់សម្រាកលោកប្រធាន ការជំទាស់របស់ខ្ញុំគឺថា សហព្រះរាជអាជ្ញា -- សុំៗតែឃ្លាទេលោកប្រធាន ខ្ញុំនឹង

បញ្ចប់ហើយ។ សូមអភ័យទោសលោកប្រធានដែលខ្ញុំនិយាយលឿនពេក។ ERN ជាភាសាអង់គ្លេសគឺ 00290263, ជាភាសាខ្មែរ 00079101, ជាភាសាបារាំង 00774256។ នេះជាការជំទាស់ចុងក្រោយរបស់យើង គឺការជំទាស់គឺថា យើងឃើញហើយគឺសហព្រះរាជអាជ្ញាគាត់ព្យាយាមបង្ហាញអំពីចំណារនេះ ដើម្បីបង្ហាញថា ប្ដីត្រូវបានគេកំណត់ថាជាគោលដៅទាហានលន់ នល់។ ក៏ប៉ុន្តែ តាមពិតទៅយើងមិនអាចទាញសេចក្ដីសន្និដ្ឋានចេញពីចំណារខ្លីនេះទេ យើងមិនអាចទាញចំណារហ្នឹងមកជាមូលហេតុនៃការសម្លាប់ប្ដីទេ ពីព្រោះថានៅក្នុងឯកសារនេះមិនមានបញ្ជាក់បែបនេះឡើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះសូមអញ្ជើញចូលវិញ ដើម្បីការកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៤ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីបន្តការងាររបស់ខ្លួន។ សូមអញ្ជើញ!

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ គឺថាមានសំណើសុំឲ្យខ្ញុំនិយាយយឺតៗបន្តិច ខ្ញុំនឹងនិយាយយឺត។ លោកប្រធាន ឯកសារបន្ទាប់ គឺឯកសារ E3/2281 និងឯកសារ E3/2262 ឯកសារទាំងពីរហ្នឹងត្រូវគេរៀបរាប់ថាជាបញ្ជីខ្មែរក្រោម។ បាទ ឥឡូវនេះគឺយើងយល់ហើយ គឺឯកសារទាំងពីរនេះ គឺជាឯកសារពីរក្នុងចំណោមបី ដែលគេហៅថាកំណត់ត្រាពីស្រុកត្រាំកក់ ដែលមានឯកសារដើមនៅឯសារមន្ទីរ

ទូលស្ដែង។ អាស្រ័យហេតុនេះ ពាក់ព័ន្ធទៅនឹងការព្រួយបារម្ភរបស់យើងខ្ញុំ អំពីខ្សែសង្វាក់នៃការបញ្ជា នៅក្នុងស្រុកត្រាំកក់ទាំងស្រុងតែម្ដង យើងស្នើសុំឱ្យអង្គជំនុំជម្រះយកឯកសារដើមមកដាក់បញ្ចូលនៅក្នុងសំណុំរឿង។ ហើយបន្ថែមលើនេះ យើងខ្ញុំយល់ឃើញថាបញ្ជីទាំងអស់នេះ គឺគ្រាន់តែជាបញ្ជីទេមិនមែនជាបញ្ជីអ្នកទោស ឬក៏បញ្ជីអ្នកទោសដែលត្រូវសម្លាប់នោះទេ។ ឯកសារមួយ គឺមកពីឃុំត្រពាំងធំខាងជើង និងមួយទៀតមកពីឃុំពពេល។ ដូច្នេះ អ្វីដែលព្រះរាជអាជ្ញាចង់លើកឡើង គឺពិតជាមានការពាក់ព័ន្ធ ឬយ៉ាងណានោះក៏អត់នោះទេ បើមិនមានភស្តុតាងជាក់ស្ដែងណាមួយបន្ថែមទៅលើបញ្ជីនេះទេ ការយោងទៅលើឯកសារនេះគឺថាវាមានផលវិបាក ហើយនិងមានតម្លៃជាភស្តុតាងសូន្យតែម្ដង មិនមានតម្លៃនោះទេ។ ហើយនៅក្នុងផ្នែកនេះពាក់ព័ន្ធទៅនឹងការប្រព្រឹត្តមកលើប្រជាជនវៀតណាមនិងខ្មែរក្រោម សហព្រះរាជអាជ្ញាបានធ្វើការយោងដំបូងទៅលើឯកសារ E3/2048 ជាឯកសារមួយដែលគេបានលើកឡើងដដែលនៅក្នុងធ្វើការបទបង្ហាញអំពីឯកសារនេះ។

[១០:៣៤:១៥]

នៅក្នុងការយោងដំបូង សហព្រះរាជអាជ្ញាបានលើកឡើងនៅទំព័រមួយដែលបានរៀបរាប់ថាជាបញ្ជីមកពីឃុំពពេល ចុះខែឧសភា ១៩៧៥ ស្ដីអំពីប្រជាជនខ្មែរក្រហមចំនួន៦៤គ្រួសារ ដែលជម្លៀសមកពីប្រទេសវៀតណាម។ លោកប្រធាន នៅត្រង់ចំណុចនេះ គឺថាជាជំទាស់តវ៉ារបស់យើងខ្ញុំទាក់ទងទៅនឹងទម្រង់នៃឯកសារនេះ។ ឯកសារ E3/2048 មិនមែនគ្រាន់តែជាឯកសារថតចម្លងទេ ហើយមិនមានឯកសារដើមទេ ក៏ប៉ុន្តែហាក់បីដូចជាការថតចម្លងជាន់ទៅលើការចម្លងម្ដងរួចមកហើយ។

បន្ថែមទៅលើឯកសារដែលបានលើកឡើង ជាការឆ្លើយឆ្លងគ្នាទៅវិញទៅមកម្ដងហើយម្ដងទៀតនេះ ហើយមិនមានការប្រមូលនូវឯកសារទាំងអស់នោះ ឬបង្ហាញឯកសារណាមួយនោះទេ។ ដូច្នេះបញ្ហាថាតើអ្នកណា នៅពេលណា ហេតុអ្វី និងដោយរបៀបណាដែលឯកសារទាំងអស់នេះ មានសារៈសំខាន់នោះទៅបាននោះ។ ឯកសារទាំងអស់នេះ និងជាមួយការយោងយ៉ាងច្រើនទៅលើឯកសារនោះដូច្នេះ យើងខ្ញុំមានការព្រួយបារម្ភអំពីភនីយហេតុ និងតម្លៃនៃភស្តុតាង ស្នើសុំឱ្យអង្គជំនុំជម្រះស្វែងរកឯកសារដើមនៃឯកសារនេះ។ លើសពីនេះទៅទៀត ដូចដែលបានលើកឡើងនូវបញ្ជីខាងដើមដោយមិនមានភស្តុតាងច្បាស់លាស់ណាមួយអំពីអ្វីកើតឡើងទៅលើប្រជាជនដែលមានឈ្មោះនៅលើបញ្ជីនោះទេ។ ដូច្នេះ ការគ្រាន់តែមានបញ្ជីនេះមួយ គឺវាមិនមានភាពពាក់ព័ន្ធអ្វីទាល់តែសោះ។

សហព្រះរាជអាជ្ញាក៏បានលើកឡើងនៅផ្នែកមួយពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើជនជាតិ

វៀតណាម និងខ្មែរក្រោម ដែលគាត់បានយោងទៅលើរបាយការណ៍របស់ ហង់រី ឡូកា ហៅថា "ស្រុកត្រាំកក់នៅក្នុងកណ្ដាប់ដៃរបស់ខ្មែរក្រហម" គឺឯកសារ D313/1.2.16។ បន្ថែមទៅលើការជំទាស់ជាទូទៅនេះ ខ្ញុំបានលើកឡើងរួចមកហើយពាក់ព័ន្ធទៅនឹងរបាយការណ៍នេះ យើងខ្ញុំសូមជំទាស់ទៅនឹងរបាយ-ការណ៍របស់ ហង់រី ឡូកា ផងដែរ ដែលថាវាមិនពាក់ព័ន្ធនោះទេ គាត់គ្រាន់តែធ្វើអ្វីមួយ ដូចដែលយើងកំពុងតែធ្វើ ដូចដែលយើងធ្វើដែរ គឺគាត់វិភាគទៅលើកំណត់ត្រាដែលសល់ពីស្រុកត្រាំកក់។

[១០:៣៦:៤៨]

លើសពីនេះទៅទៀត ការជំទាស់តវ៉ាថាតើ ហង់រី ឡូកា ជាអ្នកជំនាញឬក៏អត់? នេះគឺថាវាអាចបន្ថែមតម្លៃនៃភស្តុតាងទៅលើការវិភាគនេះបាន។ សហព្រះរាជអាជ្ញាបានកំណត់ចរិតលក្ខណៈ ហង់រី ឡូកា សូមដកស្រង់ "ជាអ្នកប្រវត្តិសាស្ត្រ" បិទការដកស្រង់។ សូមដកស្រង់ "ជាអ្នកវិទ្យាសាស្ត្រនយោបាយ" ហើយសូមដកស្រង់ "ក៏ជាអ្នកជំនាញនាំមុខស្តីអំពីប្រទេសកម្ពុជានិងខ្មែរក្រហម" សូមបិទការដកស្រង់។ គឺឯកសារ E305/6.4, ERN ជាភាសាអង់គ្លេស 00986615, 00997433 ជាភាសាបារាំង ហើយ ERN ជាភាសាខ្មែរគឺមិនទាន់មាននៅឡើយទេ។ ក៏ប៉ុន្តែតាមការយល់ឃើញរបស់យើងខ្ញុំ គឺហង់រី ឡូកា បានយល់ស្របទៅលើភាសាអង់គ្លេស ការវិភាគរបស់គាត់ទៅលើភាសា -- កម្រិតនៃភាសាអង់គ្លេស។ ហេតុដូច្នេះ វាមិនច្បាស់ថាតើគាត់អាចមានការវាយតម្លៃយ៉ាងដូចម្តេច។ គាត់មានចំណាយពេលយ៉ាងច្រើននៅក្នុងប្រទេសកម្ពុជា ពាក់ព័ន្ធទៅនឹងបញ្ហានៃខ្មែរក្រហម និងបញ្ហានៃសមាជិកខ្មែរទូទៅ។

សហព្រះរាជអាជ្ញាក៏បានទទួលយកបន្ថែមទៀតផងដែរ ថាសេចក្តីសង្ខេបរបស់ ហង់រីឡូកា នេះ គឺ ក្រេក អេចឆេសាន់ នេះទៀត គឺថាសក្ខីកម្មរបស់គាត់ក៏យើងត្រូវយកមក -- គាត់និយាយអំពីបញ្ហាមួយដែលហៅថា "អំបិលមួយគ្រាប់" ហើយដូច្នេះ ក៏កំណត់សក្ខីកម្មរបស់ ហង់រី ឡូកា ប្រវត្តិនៃការធ្វើកិច្ចការរបស់គាត់គឺថាមិនមានគុណវុឌ្ឍិដែលមាន អាចឲ្យជាប់ពាក់ព័ន្ធបានទេ។

ឥឡូវនេះ ខ្ញុំសូមចូលទៅប្រធានបទមួយទៀត និយាយអំពីការប្រព្រឹត្តមកលើទាហាន និងមន្ត្រីរដ្ឋការរបបលន់ នល់។

*(គ្មានការបកប្រែ)*

[១០:៣៩:១១]

**ប្រធានអង្គជំនុំ៖**

អត់ទាន់ អត់មានការបកប្រែភាសាទេ។

បាទ សូមធ្វើឡើងវិញនៃចំណុចចុងក្រោយអំមិញ លោកមេធាវី វ៉ិចទ័រ កូប៉េ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ អ៊ីចឹងខ្ញុំសូមចាប់ផ្តើម និយាយអំពីការផ្តល់ការយកចិត្តទុកដាក់ ទី៣ របស់សហព្រះរាជអាជ្ញា ដែលនិយាយអំពីការប្រព្រឹត្តទៅលើទាហាន និងមន្ត្រីរដ្ឋការលន់ នល់ នៅស្រុកត្រាំកក់ និងនៅក្រាំងតាចាន់។ មុននឹងខ្ញុំធ្វើការជំទាស់ជាក់លាក់ណាមួយទៅលើឯកសារ ខ្ញុំសូមលើកឡើងនូវការជំទាស់ជាទូទៅ ដែលថាសូម្បីតែមន្ត្រី និងទាហាន លន់ នល់ ដែលត្រូវជាគោល -- កំណត់ជាគោលដៅក៏ដោយ។ នេះយើងនិយាយអំពីបរិបទនយោបាយ។ ការកំណត់គោលដៅនេះ បើសិនណាវាជាកើតឡើងវាមិនមានអ្វីប្លែកទេ ដោយសារតែភាពភ័យខ្លាចនៃសង្គ្រាម លន់ នល់ ដែលធ្វើឲ្យកម្ពុជាប្រជាធិបតេយ្យមានការយល់ឃើញបែបនេះ។ ជាការពិតហើយនៅប្រទេសខ្លះលក្ខណៈបែបនេះមានការធ្វើឡើងដូចៗគ្នាអ៊ីចឹង។

[១០:៤០:៤២]

ទាក់ទងទៅនឹងឯកសារ E3/2120 របស់ សៀវភៅរបស់លោក អៀ ម៉េងទ្រី ហៅថា "ខ្មែរសង្ខាក់នៃការភ័យខ្លាច"ហើយយើងខ្ញុំក៏សូមការជំទាស់ដែរចំពោះការលើកឡើងដោយសហព្រះរាជអាជ្ញានូវឯកសាររបស់ អៀ ម៉េងទ្រី នេះ។ បន្ថែមទៅលើការជំទាស់ទូទៅ យើងក៏ស្នើសុំឲ្យកោះហៅលោក អៀ ម៉េងទ្រី មកផ្តល់អំពីវិធីសាស្ត្ររបស់គាត់ក្នុងការស្រាវជ្រាវឯកសារនេះ ជាពិសេសពាក់ព័ន្ធទៅនឹងឯកសារនៃការសិក្សាស្រាវជ្រាវស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ហើយយើងខ្ញុំក៏បានកត់សម្គាល់ផងដែរនៅក្នុងសំណុំរឿង គឺថាវាជាសេចក្តីព្រៀងលឿនពេកហើយនៃសៀវភៅរបស់ អៀ ម៉េងទ្រី ហ្នឹងដែលមានការផ្តល់ជាមតិយោបល់ និងសំណើផ្សេងៗមកពី យុ ឆាំង ដែលគាត់គឺជាប្រធានមជ្ឈមណ្ឌលឯកសារ – នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ បុគ្គលម្នាក់ទៀតដែលគេកំណត់អត្តសញ្ញាណថា ស្ទីវ ប្រហែលជា ស្ទីវ ហេដឌ័រ នេះហើយ និងអ្នកនិពន្ធទី៣ទៀត ដែលម្នាក់ទៀតទី៣មិនស្គាល់អត្តសញ្ញាណ។ ហើយយើងខ្ញុំសូមឲ្យអង្គជំនុំជម្រះមេត្តាយកចិត្តទុកដាក់ទៅលើមតិយោបល់នេះ។ នៅក្នុងសារមួយនោះ អៀ ម៉េងទ្រី បានយោងថាតើគាត់ អ្នកដែលគាត់ត្រូវបានសម្ភាសនោះឈ្មោះ ឃុត នោះបានរៀបរាប់អំពីៗឈ្លបនៅឃុំ ពាក់ព័ន្ធទៅនឹងការភ្ជួរស្រែជាមួយនឹងអ្នកដែលមិនមែន

ជាអ្នកទោស "សូម្បីតែអ្នកដែលមិនទទួលការស្តីបន្ទោសអី ក៏ត្រូវធ្វើការយ៉ាងលំបាកដែរ ដូច្នេះអ្នកទោសក៏ត្រូវបានគេបង្ខំឱ្យធ្វើការកាន់តែពិបាកឡើង"។ បញ្ចប់ការដកស្រង់។

[១០:៤២:៣៤]

ហើយភ្លាមៗចេញពីចំណាររបស់ យុ ឆាំង ដែលសរសេរថា សូមដកស្រង់ "អ្នកដឹងទេ ខ្ញុំមិនចូលចិត្តកថាខណ្ឌនេះ ដែលធ្វើឱ្យអ្នករស់រានមានជីវិត គឺថាមើលទៅដូចជាខ្សោយណាស់ ប្រជាជនត្រូវធ្វើការយ៉ាងលំបាក។ ដូច្នេះខ្ញុំសំដៅទៅលើសិទ្ធិរបស់ប្រជាជន សិទ្ធិនិងសេរីភាពរបស់ប្រជាជនដែលត្រូវបានគេដកហូតយកចេញ ឬក៏អាចលុបកថាខណ្ឌនេះតែម្តង" សូមចប់។ ឯកសារហ្នឹងគឺឯកសារ E3/2120 នៅក្នុងសំណុំរឿងដែល ERN ជាភាសាអង់គ្លេស 00105683។ ទោះបីជា អៀ ម៉េងទ្រី នៅរក្សាឃ្លារបស់ -- សាររបស់គាត់នៅក្នុងរបាយការណ៍ចុងក្រោយរបស់គាត់ នេះក៏ជាឧទាហរណ៍បញ្ជាក់ថា គឺត្រូវបានគេទទួលយកជាទូទៅ ហើយអ្នកទាំងអស់នេះគឺគេចាត់ទុកគ្រាន់តែជាក្រុមនៃអ្នកដែលផ្តល់ប្រឹក្សាតែប៉ុណ្ណោះ។ បន្ថែមទៅលើរបាយការណ៍របស់ ហង់រី ឡូកា បន្ថែមទៅលើសេចក្តីសន្និដ្ឋានរបស់ អៀ ម៉េងទ្រី ចេញអំពីការវិភាគទៅលើកំណត់ត្រានៅស្រុកត្រាំកក់នោះ។ ដូច្នេះយើងខ្ញុំសូមជំទាស់ថា សេចក្តីសន្និដ្ឋានទាំងអស់នេះគឺមិនជាប់ពាក់ព័ន្ធទេ។ លើកលែងតែសហព្រះរាជអាជ្ញាអាចបង្ហាញចំណុចណាដោយប្រកបទៅដល់ហេតុផលជូនអង្គជំនុំជម្រះ ពាក់ព័ន្ធទៅនឹងអ្នកការជំនាញវិភាគរបស់គាត់នេះ។ ជាការពិតហើយ អៀ ម៉េងទ្រី បានធ្វើការសម្ភាស ខ្លឹមសាររបស់វាអាចមានជាប់ពាក់ព័ន្ធ ក៏ប៉ុន្តែក្នុងករណីនេះ គឺថាជាការចាំបាច់ណាស់គឺត្រូវកោះហៅគាត់មកសួរ សក្ខីកម្មរបស់គាត់អំពីវិធីសាស្ត្រក្នុងការសិក្សាស្រាវជ្រាវនេះ។

[១០:៤៤:២៥]

ឯកសារបន្ទាប់ដែលយើងខ្ញុំបានយោងនៅក្នុងផ្នែកនេះ ដែលយើងហៅថា "ការកំណត់គោលដៅទៅលើទាហាននិងមន្ត្រីរដ្ឋការលន់ នល់" គឺឯកសារ E3/4095។ នេះគឺឯកសារសួរចម្លើយមកពីក្រាំងតាចាន់ -- សៀវភៅកត់ត្រាសួរចម្លើយមកពីគុកក្រាំងតាចាន់ ហើយឯកសារនេះយើងបានយោងយ៉ាងច្រើននៅក្នុងការបង្ហាញ បទបង្ហាញឯកសាររបស់យើងខ្ញុំ។ ប៉ុន្តែយើងខ្ញុំសូមធ្វើការជំទាស់ដូចតទៅទាក់ទងទៅនឹងការប្រើប្រាស់ឯកសារនេះពីសំណាក់សហព្រះរាជអាជ្ញា។ ទី១ យើងកត់សម្គាល់ឃើញថាទំព័រខាងដើមនៃឯកសារនេះ គឺមានចំណងថា "ចម្លើយសារភាពទី៥ របស់អាក្បត់ជាតិ ប៉ុល ពត និងអៀង សារី – របស់អាក្បត់ ប៉ុល ពត និងអៀង សារី" បញ្ចប់ការដកស្រង់។ វាជាចំណងជើងដែល

បន្ថែមទៅលើរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែឯកសារនេះ គឺថាវាមានការជាប់ប្រទ្បាក់ប្រទ្បុស។ បន្ថែមទៅលើនេះ គឺថាសេចក្តីសង្ខេបរបស់ព្រះរាជអាជ្ញាទាក់ទងទៅនឹងភាពពាក់ព័ន្ធនៃឯកសារនេះ នៅក្នុងចំណោមបញ្ហាជាច្រើន ពាក់ព័ន្ធទៅនឹងការចាប់ខ្លួនអ្នកទោសមួយចំនួន។ នៅត្រង់ចំណុចនេះ ខ្ញុំយល់ឃើញថាបទដ្ឋានទ្វេរនេះ គឺថាត្រូវបានគេយកមកប្រើប្រាស់ ទាក់ទងទៅនឹងការសួរចម្លើយ និង ចម្លើយសារភាពរបស់អ្នកទោស។ យើងឃើញថាសហព្រះរាជអាជ្ញាហាក់បីដូចជាយោងតែទៅលើ ខ្លឹមសារនៃចម្លើយសារភាពនេះតែប៉ុណ្ណោះ។

[១០:៤៥:៥៥]

សេចក្តី -- ការដាក់បញ្ចូលឯកសារនេះ ទៅនៅផ្នែកមួយរបស់សហព្រះរាជអាជ្ញាស្តីអំពីការ កំណត់គោលដៅទៅលើទាហាននិងមន្ត្រីរដ្ឋការលន់នល់នោះ បានធ្វើឱ្យយើងខ្ញុំលើកឡើងនូវចំណុចមួយ ចំនួនពាក់ព័ន្ធទៅនឹងឯកសារនេះ។ ទី១ នៅពេលដែលពិនិត្យទៅលើខ្លឹមសារនៃចម្លើយសារភាពនៅក្នុង ឯកសារនេះ គឺមើលទៅហាក់បីដូចថាគ្មានអ្នកណាម្នាក់នៅក្នុងនេះ នៅក្នុងឯកសារនេះ ត្រូវបានសួរ ចម្លើយដើម្បីកំណត់អំពីឋានន្តរសក្តិរបស់គេនៅក្នុងទាហានរបបលន់ នល់ នៅក្នុងរដ្ឋបាល លន់ នល់ នោះទេ។ ដោយសារតែអ្នកទាំងអស់នេះត្រូវបានគេយល់ឃើញថា បានធ្វើអ្វីមួយ។ នេះត្រូវបានលើក ឡើងដោយឧទាហរណ៍ទី១ នៅក្នុងសៀវភៅនេះ។ បញ្ហានេះពាក់ព័ន្ធទៅនឹងបុរសម្នាក់ឈ្មោះ យួន ហេង ជាកូនទាហាន ដែលត្រូវបានចោទប្រកាន់។ សូមដកស្រង់៖ “ជាកម្មាភិបាលនៅខាងផ្នែកពាណិជ្ជកម្ម ហើយមានបំណងគឺថាកាប់គាត់ឱ្យដល់ស្លាប់”។ ERN ជាភាសាអង់គ្លេស 00747237, ខ្មែរ 0027 1090, បារាំង00721206។ យើងអាចប្រៀបធៀបឯកសារនេះជាមួយនឹងឧទាហរណ៍ផ្សេងទៀត ដែល អង្គជំនុំជម្រះបានជម្រាបមកហើយ រួមទាំងមនុស្សដែលត្រូវបានគេលើកឈ្មោះឡើងនៅក្នុងសៀវភៅ កត់ត្រាដដែលនេះ ដែលមិនមែនជាទាហាន ឬមិនមែនជាមន្ត្រីរដ្ឋការលន់នល់ នោះទេ។ មានឧទាហរណ៍ មួយយើងបានពិភាក្សាយ៉ាងវែង ទាក់ទងទៅនឹងសមាជិកក្រុមគ្រួសាររបស់ មាស សុខា។ អ្នកទាំងពីរ នេះមិនត្រូវបានចាប់ខ្លួនដោយខុសច្បាប់ ឬតាមទំនើងចិត្ត ប៉ុន្តែត្រូវខាងថ្នាក់ឃុំរកឃើញថាគាត់ព្យាយាម ទម្លាក់ បះបោរទម្លាក់មេឃុំ។

[១០:៤៧:៥៨]

ទី២ សៀវភៅមួយដែលមានសេចក្តីសង្ខេបពាក់ព័ន្ធទៅនឹងការសួរចម្លើយរបស់ឈ្មោះ វ៉ាត់។ ទី២ សៀវភៅទី២នេះ គឺជាសេចក្តីសង្ខេបអំពីការសួរចម្លើយ ជាមួយគ្នានេះ គួរត្រូវបានពិចារណាថា

ភស្តុតាងមួយមិនគ្រប់គ្រាន់ទេ ដោយសារតែមូលហេតុនៃការចាប់ខ្លួនរបស់បុគ្គលម្នាក់នេះបានទេ។ អ្វីដែលយើងចង់ប្ដឹងនោះ ឧទាហរណ៍គឺឯកសារមកពីទីតាំងដែលត្រូវគេផ្ញើទៅ និងឯកសារដែលបញ្ជាក់ថា តើមានអ្វីកើតឡើងទៅនឹងប្រជាជនបន្ទាប់ ដូចជាការសម្លាប់ ឬក៏បញ្ជីនៃការដោះលែងជាដើម។

ការជំទាស់របស់យើងខ្ញុំទៅលើចំណុចនេះ ក៏អនុវត្តចំពោះឯកសារដទៃទៀត ដែលសហព្រះរាជអាជ្ញាបានប្រើនៅក្នុងផ្នែកនៃការបង្ហាញឯកសាររបស់ខ្លួន។ គឺឯកសារ E3/2107, E3/2048 និង E3/2332។ អនុញ្ញាតឱ្យខ្ញុំបន្ថែមនូវការផ្ដល់យោបល់មួយចំនួនទៅលើឯកសារ E3/2048។ ឯកសារជាក់លាក់នេះ គឺនៅក្នុងកម្រងឯកសារដែលសហព្រះរាជអាជ្ញាបានយោងនៅក្នុងការបង្ហាញរបស់ខ្លួន គឺរបាយការណ៍ពីឃុំតាភេម ចុះខែមេសា ១៩៧៧ ឈ្មោះ គៀត ផ្ញើជូនអង្គការ ERN ជាភាសាអង់គ្លេស 00276564, ខ្មែរ 00079791 និងបារាំង 00611611។ ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងហើយ ឯកសារនេះហាក់បីដូចជាលើកឡើងថាទាហានលន់ នល់ ត្រូវបានកំណត់អត្តសញ្ញាណទៅលើមូលដ្ឋាននៃអត្តសញ្ញាណរបស់ពួកគេនៅពេលនោះ។

[១០:៤៩:៥៤]

ជាការពិតហើយ ឥឡូវនេះ ការជំទាស់ទូទៅរបស់យើងខ្ញុំក៏អនុវត្តជាមួយឯកសារនេះដែរ ហើយតម្រូវឱ្យមានការភស្តុតាងបន្ថែម ស៊ីចង្វាក់គ្នាទាក់ទងទៅនឹងជោគវាសនារបស់មនុស្សដែលគេកំណត់អត្តសញ្ញាណនៅក្នុងឯកសារនេះ។ ក៏ប៉ុន្តែឯកសារនេះ និងកាលបរិច្ឆេទរបស់វាក៏ជារឿងមួយដែលសំខាន់ដែរ។ នេះគឺដោយសារថា ចេញពីពាក់កណ្ដាលឆ្នាំ១៩៧៧មក ហាក់បីដូចជាថា មានការកែប្រែមួយយ៉ាងហោចណាស់ក៏នៅក្នុងកំណត់ត្រាពីស្រុកត្រាំកក់ដែលប្រជាជនត្រូវបានកំណត់ដោយយោងទៅលើបុណ្យស័ក្តិនៅក្នុងជួរទាហាន ឬក៏ជួររដ្ឋបាលនៃអតីតរបបលន់ នល់។ ដូចយើងបានឃើញហើយ ឯកសារប្រភេទនេះ ហាក់បីដូចជាមិនមាននៅមុនពេលនោះទេ។ ហេតុដូច្នេះ យើងខ្ញុំសុំស្នើថាវាអាចមានរយៈពេលពីរខុសគ្នា គឺនៅមុន និងក្រោយពាក់កណ្ដាលឆ្នាំ១៩៧៧ ដែលហាក់បីដូចថា វាស៊ីចង្វាក់គ្នាទៅនឹងសក្ខីកម្មរបស់ ពេជ្រ ជឹម កាលពីថ្ងៃសុក្រ និងចម្លើយរបស់កម្មាភិបាលភូមិភាគនិរតី មួយដែលបានឆ្លើយថា "ភ្លាមៗក្រោយពីការរំដោះ" ដែលនៅក្នុងពេលនោះ តាម៉ុក និយាយសូមដកស្រង់ "ទាហានជាមួយនឹងបុណ្យស័ក្តិពី ស័ក្តិ២ទៅស័ក្តិ៥ហ្នឹងគឺថាមិនត្រូវប៉ះពាល់ទេ" បញ្ចប់ការស្រង់។ នេះគឺច្បាស់ហើយ គឺថាវាជាបញ្ហាពាក់ព័ន្ធទៅនឹងទាហាន មន្ត្រីរដ្ឋការលន់ នល់ ដែលត្រូវបានគេកំណត់ជាគោលដៅជាក់ស្ដែងគឺថា វាត្រូវតែពាក់ព័ន្ធទៅនឹងកំណត់ត្រាមកពីស្រុកត្រាំកក់ដែលត្រូវធ្វើការពិនិត្យ

ពិច័យឲ្យបានច្បាស់មុននឹងអាចយកមកសំអាងថាជាភស្តុតាងគន្លឹះ ឬក៏មុននឹងឈានទៅដល់ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ណាមួយ។

[១០:៥១:៥៧]

ប្រធានបទមួយទៀត ពាក់ព័ន្ធទៅនឹងឯកសារដដែល E3/2048 ខ្ញុំកត់សម្គាល់ឃើញថា នៅក្នុងការបង្ហាញឯកសារ សហព្រះរាជអាជ្ញាបានលើកឡើងសារមួយនៅក្នុងឯកសារមួយផ្សេងទៀត នៅក្នុងកម្រងឯកសារនេះ គឺរបាយការណ៍ចុះថ្ងៃទី២ ឧសភា ១៩៧៧ មកពីឈ្មោះ ផន ឃុំពពេល។ ERN ជាភាសាអង់គ្លេស 00376563 ដល់ 4, ខ្មែរ 00079090, បារាំង00611661។ នៅក្នុងសារដែលពាក់ព័ន្ធចំណុចពីរនៃរបាយការណ៍នេះ ផន បានរាយការណ៍ថា សូមដកស្រង់៖ “គ្រួសារទាហាន១០៦គ្រួសារត្រូវបានអង្គការកម្ទេចចោលហើយ រួមទាំងអ្នកដែលបានស្លាប់នោះផង សរុបទាំងអស់ទៅគឺមានមនុស្ស៣៩៣នាក់” បញ្ចប់ការដកស្រង់។

នៅលើប្រធានបទនេះ ខ្ញុំសូមយោងមួយទៀតទៅលើសក្ខីកម្មរបស់សាក្សី ពេជ្រ ជឹម នៅក្នុងសវនាការកាលពីសប្តាហ៍មុនដូចដែលអង្គជំនុំជម្រះជ្រាបហើយ ពេជ្រ ជឹម បានពន្យល់ពាក្យ “កម្ទេច” ហ្នឹងគឺថាមានន័យពីរ ទី១ យោងទៅលើការបោសសម្អាត និយាយអំពីសតិអារម្មណ៍មិនជ្រះស្រឡះរបស់គេ ដែលមានន័យ១ ហើយជំហររបស់អង្គជំនុំជម្រះទៅលើពាក្យ “កម្ទេច” នៅក្នុងសំណុំរឿង ០០១ គឺយើងផ្តោតទៅលើសក្ខីកម្មរបស់ ឌុច។ ក៏ប៉ុន្តែ ឧបមាថាវាជាការពិតថា ពាក្យ “*ស្មាស*” ហ្នឹងវាអាចមានន័យខុសផ្សេងៗរបស់កម្ពុជាប្រជាធិបតេយ្យ យើងខ្ញុំសូមជំទាស់ថាសក្ខីកម្មរបស់ ពេជ្រ ជឹម ទាក់ទងទៅនឹងពាក្យ “*ស្មាស*” នេះគឺថា វាពាក់ព័ន្ធទៅនឹងស្ថានភាពរបស់យើងនេះ ច្រើនជាងសក្ខីកម្មរបស់ ឌុច។ ហេតុអ្វី? ពេជ្រ ជឹម គឺជាលេខារបស់ស្រុកត្រាំកក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយឯកសារហាក់បីដូចថា សេចក្តីណែនាំពាក់ព័ន្ធទៅនឹងជោគវាសនារបស់ប្រជាជន គឺថា គេស្នើសុំមកតែពីមតិពីថ្នាក់ស្រុកតែប៉ុណ្ណោះ។ បន្ថែមទៅលើនោះ គឺអង្គជំនុំជម្រះពិចារណាទៅលើគាត់ថា ពេជ្រ ជឹម នេះ ជាសាក្សីមួយដែលគួរឲ្យជឿជាក់បាន។

យោងទៅតាមការរៀងរ៉ាវរបស់យើង អង្គជំនុំជម្រះបានយោងទៅលើសក្ខីកម្មរបស់ ពេជ្រ ជឹម ចំនួន១៦ដងនៅក្នុងសំណុំរឿង ០០២/០១ – នៅក្នុងសាលក្រម ០០២/០១។ ពាក់ព័ន្ធទៅនឹងការកំណត់និយមន័យនៃពាក្យ “*ស្មាស*” ដោយ ពេជ្រ ជឹម នេះគឺការយោងទៅការកម្ទេចក្រុមគ្រួសារយោធា។ នៅក្នុងឯកសារ E3/2048 ប្រហែលជាមិនមានន័យថា“សម្លាប់”ទេ។ ប្រហែលជាមានន័យថា និយាយថា

បញ្ជូនទៅអប់រំ មជ្ឈមណ្ឌលអប់រំកែប្រែ ឬក៏បញ្ជូនទៅកន្លែងមួយផ្សេងទៀតតែប៉ុណ្ណោះ។ នៅក្នុងករណីដទៃទៀត វាតម្រូវឲ្យមានការស៊ើបអង្កេតមុននឹងធ្វើសេចក្ដីសន្និដ្ឋានណាមួយទៅលើពាក្យនេះ។

[១០:៥៤:៥៧]

លោកប្រធាន ឥឡូវនេះខ្ញុំសូមធ្វើការជំទាស់ខ្លីទេ ទាក់ទងទៅនឹងឯកសារទៅលើផ្នែកចំនួនប្រាំបន្ទាប់ដែលសហព្រះរាជអាជ្ញាបានផ្ដោតការយកចិត្តទុកដាក់នៅក្នុងការបង្ហាញឯកសាររបស់ខ្លួននេះ។ ទី១ ទាក់ទងទៅនឹងការប្រព្រឹត្តនិងការកំណត់គោលដៅទៅលើប្រជាជនថ្មីនៅក្នុងស្រុកត្រាំកក់។ ការជំទាស់ទូទៅរបស់យើងនឹង គឺសហព្រះរាជអាជ្ញាមិនបានបង្ហាញឯកសារណាមួយ បង្ហាញថាមានគោលនយោបាយប្រព្រឹត្តមកលើប្រជាជនថ្មីខុសពីអ្នកដទៃទៀតនោះទេ។ ទោះបីខ្ញុំមិនអនុញ្ញាតឲ្យលើកឡើងវិញនូវអ្វីដែលសហព្រះរាជអាជ្ញានិយាយក៏ដោយ យើងមានពាក្យពីគណៈអចិន្ត្រៃយ៍ គឺពាក្យដ៏សំខាន់ពីគណៈអចិន្ត្រៃយ៍មក ដែលត្រូវបានជំទាស់តវ៉ាថា គឺថា អចិន្ត្រៃយ៍និយាយថា “អាចមានសមាសភាពមិនល្អនៅក្នុងចំណោមប្រជាជនថ្មី ប្រជាជនថ្មីទាំងអស់មិនមែនអាក្រក់ទាំងអស់នោះទេ”។ នេះគឺជាចំណុចរបស់យើងដែលយើងបានធ្វើការប្ដឹង -- ធ្វើការជំទាស់តវ៉ានោះ។

ចំណុចមួយទៀត គឺនិយាយប្រជាជនដែលត្រូវចាប់ខ្លួនដោយសារតែប្រឆាំង ឬក៏ទិតៀនបដិវត្តន៍ ទិតៀនបក្ស ឬទិតៀនអង្គការទាក់ទងទៅនឹងការចាប់ខ្លួនប្រជាជនដែលបានជំទាស់ ឬក៏រិះគន់បដិវត្តន៍ ឬបក្ស ឬក៏អង្គការ។ យើងកត់សម្គាល់ឃើញថា គឺមាននៅក្នុងឯកសារ E3/4095, E3/2107 និងឯកសារ D157.7 ដែលឥឡូវនេះគឺថា ទៅជាឯកសារថ្មីនេះគឺ E3/5827។

[១០:៥៦:៤៥]

ជាថ្មីម្ដងទៀត យើងខ្ញុំសូមបង្ហាញនូវការជំទាស់ដំបូង សៀវភៅកត់ត្រាដែលយើងខ្ញុំថា វាមាន -- វាសំខាន់ណាស់ ត្រូវមានឯកសារផ្សេងទៀតយកមកបង្ហាញទៅលើសៀវភៅកត់ត្រានៃការសួរចម្លើយអ្នកទោស ធ្វើយ៉ាងម៉េចដើម្បីឲ្យវាស៊ីចង្វាក់គ្នា ពាក់ព័ន្ធទៅនឹងជោគវាសនារបស់ប្រជាជននេះ។ បើមិនដូច្នេះទេ តម្លៃនៃភស្តុតាងនៅក្នុងសៀវភៅកត់ត្រានេះតែឯង គឺវាមានកម្រិតបំផុត។

ឯកសារបន្ទាប់មកទៀតគឺនិយាយអំពីប្រជាជនដែលត្រូវបានចាប់ខ្លួន ជាប់ទាក់ទងទៅនឹងចំណីអាហារ ឬក៏លក្ខខណ្ឌការងារ។ ស្ថានភាពការងារនេះគឺទុកវាមួយអន្លើសិន។ អ្វីដែលខ្ញុំចង់លើកឡើងនេះគឺវាពាក់ព័ន្ធទៅនឹងអ្នកដែលគេចាប់ខ្លួនដោយសារតែលួចចំណីអាហារ ឬក៏ត្អូញត្អែរអំពីចំណីអាហារ ឬក៏ត្អូញត្អែរអំពីលក្ខខណ្ឌនិងការងារ។ អ្នកដែលមានមតិផ្ទុយ គឺចំណុចនេះពាក់ព័ន្ធទៅនឹងកម្មាភិបាល

ទាំងអស់ដែលបានមកផ្តល់សក្ខីកម្មរួចមក។

យើងក៏បានចង្អុលបង្ហាញទៅលើភស្តុតាងផ្សេងទៀត នៅក្នុងការបង្ហាញឯកសាររបស់យើងខ្ញុំកាលពីថ្ងៃអង្គារ ដែលបញ្ជាក់ថាវាមានការផ្ទុយគ្នា ថាប្រជាជនខ្លះអាចត្រូវបានគេអប់រំកែប្រែជាច្រើនដង។ ជាពិសេសគឺអ្នកអប់រំច្រើនដងពាក់ព័ន្ធទៅនឹងបទល្មើសធ្ងន់ធ្ងរ មិនមែនត្រឹមតែការលួចដូងប៉ុណ្ណោះទេ។ បន្ថែមពីលើនេះជាថ្មីម្តងទៀតគឺ ចាំបាច់ណាស់ថាឯកសារបន្ថែមវាអាចជារូបភាពមួយពេញលេញពាក់ព័ន្ធទៅនឹងសៀវភៅកត់ត្រាសួរចម្លើយ បង្កើតបានជាមូលដ្ឋាននៃភស្តុតាងនេះ។ ហើយវាក៏អាចផងដែរ ហើយក៏ទម្លាប់ផងដែរ ដែលថាព័ត៌មានដែលបុគ្គលម្នាក់អាចផ្តល់នៅក្នុងពេលសួរចម្លើយនោះគឺថាវាអាចជាការខុសគ្នាទាំងស្រុងទៅនឹងមូលហេតុដែលបណ្តាលឲ្យមានការចាប់ខ្លួនរបស់ពួកគាត់នោះ។

[១០:៥៨:៤៩]

ប្រធានបទមួយផ្សេងទៀត គឺប្រជាជនដែលត្រូវបានចាប់ខ្លួនដោយសារព្យាយាមរត់គេចខ្លួន ឬគាត់ដើរហើរសេរី។ ទាក់ទងទៅនឹងប្រធានបទបែបនេះគឺ យើងៗថាបើយើងពិចារណាទៅលើស្ថានភាពសន្តិសុខ ជាពិសេសផ្នែកពាក់ព័ន្ធផ្ទៃក្នុងក៏ដូចការបះបោរផ្ទៃក្នុង គឺថាវាមានការកើតឡើងហើយ ជាពិតណាស់ គឺថានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ វាជាការសមហេតុផលផងដែរ។ ហេតុអ្វីបានជាបុគ្គលម្នាក់ត្រូវបានឃុំខ្លួននៅកន្លែងមួយ ហើយរកឃើញគេបញ្ជូនទៅកន្លែងមួយផ្សេងទៀត។

ប៉ុន្តែជាថ្មីម្តងទៀត ឯកសារដែលសហព្រះរាជអាជ្ញាបានចង្អុលបង្ហាញនេះ មិនបានបញ្ជាក់ថាមានអ្វីកើតឡើងទៅនឹងសចំពោះប្រជាជនទាំងនោះទេ ក្រោយពីការចាប់ខ្លួនពួកគាត់រួចមកនោះ។ ហើយពាក់ព័ន្ធទៅនឹងការចាប់ខ្លួនកុមារៗ ហើយនិងមនុស្សចាស់ គឺវាមានឯកសារមួយដែលសហព្រះរាជអាជ្ញាបានលើកឡើងគឺឯកសារ D157.36 ដែលអង្គជំនុំជម្រះចាត់ថ្នាក់ជាឯកសារមួយថ្មី គឺE3 ដែលមានលេខ E3/8417។ ឯកសារនេះពាក់ព័ន្ធទៅនឹងរបាយការណ៍ចុះថ្ងៃទី២៣, ២៤ មីនា ១៩៧៧ ពីឃុំអង្គរកា និងពីអង្គការ។ រួមទាំងសហព្រះរាជអាជ្ញាបានលើកឡើងពីការចាប់ខ្លួន និងចម្លើយសារភាពកុមារអាយុ១០ឆ្នាំម្នាក់ដែលព្យាយាមរត់ចេញពីកង។ ការជំទាស់របស់យើងនេះ គឺថាសហព្រះរាជអាជ្ញាបានដកស្រង់ចេញពីឯកសារនេះជាច្រើនដង ពីព្រោះបើយើងមើលឯកសារនេះឲ្យពេញលេញទៅ គឺថាមានចំណុចលម្អិតៗជាច្រើនត្រូវបាន -- សហព្រះរាជអាជ្ញាមិនបានលើកឡើងទេ។ ដូច្នេះ វានាំឲ្យទិដ្ឋភាពនៃរូបភាពឯកសារនេះ មើលទៅវាមានលក្ខណៈខុសគ្នា។ សូមដកស្រង់៖ “គឺថាមានកាំភ្លើងពីរដើមហើយនិងគ្រាប់ប្រភេទ៧៩” បញ្ចប់ការដកស្រង់។ ដែលវាមិនមានរូបភាពដូចគ្នាទៅលើ គេហៅថា ភាព

គ្មានទោសពៃរ៍នៃកុមារភាព គឺនៅឯកសារ 003636 --, ERN ដែលយើងទៅលើឯកសារនេះ គឺ 00363649 ដល់ 50,ខ្មែរ 00270908 និងបារាំង 00607873។

[១១:០១:២៩]

ឥឡូវនេះ ខ្ញុំចូលទៅដល់នីតិវិធីសម្រាប់អាជ្ញាធរក្នុងការចាប់ខ្លួននិងការសម្លាប់។ សហព្រះរាជអាជ្ញាបានបង្ហាញនូវឯកសារពីរទាក់ទងទៅនឹងប្រធានបទពាក់ព័ន្ធទៅនឹងនីតិវិធីក្នុងការចាប់ខ្លួន និងការសម្លាប់ខ្លួនរបស់អាជ្ញាធរ។ ទី១ គឺរបាយការណ៍របស់ ហង់រី ឡូកា ជាថ្មីម្តងទៀតហើយ គឺពីឯកសារ D313/1.2.16។ សហព្រះរាជអាជ្ញាបានដកស្រង់សារមួយដែលបញ្ជាក់ឃើញថា មិនមានឯកសារពាក់ព័ន្ធទៅនឹងការសម្លាប់។ ដកស្រង់ “ដោយសារសង្គ្រាម”, ដកស្រង់ “ទៅលើប្រជាជនថ្មីនោះទេ” ហើយនិងដកស្រង់ “ការសម្លាប់ដោយកម្ពុជាប្រជាធិបតេយ្យដែលមានផែនការ” ហើយក្នុងនោះវាស្រដៀងគ្នាទៅនឹងរបបណាហ្ស៊ី ឬក៏ស្តាលីន ពាក់ព័ន្ធទៅនឹងបញ្ហាការិយាធិបតេយ្យ និងការសម្លាប់អ្នកទោសចំពោះ -- ចេតនារបស់គេចំពោះបក្ស។ យើងក៏សូមជំទាស់ផងដែរថា ឯកសារនេះគឺវាមិនមានភនីយ-ហេតុនោះទេ។

សម្រាប់ឯកសារទី២ គឺឯកសារមួយហៅថា *“ឌីគិន អូហ្វ ដេថ”* នេះគឺឯកសារ E3/2316R។ យើងមានការព្រួយបារម្ភជាច្រើនពាក់ព័ន្ធទៅនឹងតម្លៃនៃភស្តុតាងចំពោះឯកសារនេះ ហើយយើងខ្ញុំមានបំណងធ្វើការស៊ើបអង្កេតមុននឹងលើកឡើងនូវសារណាបញ្ចប់ការសួរដេញដោលរបស់យើងខ្ញុំ ជាពិសេសយើងឃើញហើយគំរូនេះមិនមែនជាទម្រង់គតិយុត្តទេ ក៏ប៉ុន្តែយើងត្រូវតែស៊ើបអង្កេតពាក់ព័ន្ធទៅ នឹងវិធីសាស្ត្រដែលបានធ្វើការសិក្សាស្រាវជ្រាវទៅលើឯកសារទាំងអស់នេះផងដែរ ទៅលើខ្សែភាពយន្តទាំងអស់នេះផងដែរ។

[១១:០៣:២៦]

ហើយទី២ក៏យើងត្រូវការបញ្ជាក់ឲ្យបានលម្អិត រួមទាំងអត្តសញ្ញាណរបស់ប្រជាជន ដែលគេបង្ហាញខ្លួនរបស់គាត់អំពីទីតាំង ហើយថាតើអាចំណាងជើងជាភាសាអង់គ្លេស វាត្រឹមត្រូវឬក៏អត់នោះទេ? ហើយឯកសារនេះ វាមានរយៈពេលមួយម៉ោង និងបួននាទី។ បន្ទាប់មកទៀត ការប្រើប្រាស់វិធីក្តៅសម្រាប់ការសួរចម្លើយនេះ គឺជាប្រធានបទទី៣ ចុងក្រោយរបស់ព្រះរាជអាជ្ញា ដូចដែលខ្ញុំបានបង្ហាញភស្តុតាងផ្ទុយទៅលើប្រធានបទនៅក្នុងការបង្ហាញឯកសាររបស់យើង។ ឥឡូវនេះ ខ្ញុំនឹងមិនលើកឡើងជាបន្ថែមទៀតទៅលើបញ្ហានេះទេ។

ចំណុចទី២ចុងក្រោយរបស់សហព្រះរាជអាជ្ញា គឺការប្រើប្រាស់ឯកសារពីគុកក្រាំតាចាន់ នៅក្នុងសួរចម្លើយបន្ថែមទៀត។ នៅត្រង់កន្លែងនេះ គឺសហព្រះរាជអាជ្ញាបង្ហាញឯកសារតែមួយ គឺ E3/2012 ដែលចុះថ្ងៃទី១១ ខែកក្កដា ១៩៧៧។ បាទ របាយការណ៍ចុះថ្ងៃទី១១ កក្កដា ៧៧ មកពីមេគុកឈ្មោះ អាន់ ស្ដីពីចម្លើយសារភាពរបស់អ្នកទោសម្នាក់ឈ្មោះ ស៊ីន យ៉ាង។ ឥឡូវនេះ គឺថាសហព្រះរាជអាជ្ញាបានលើកឡើងនូវឯកសារសរសេរដោយដៃពីរ ដែលមានចំណារដោយដៃពីរ ទី១ពាក់ព័ន្ធទៅនឹង ស៊ីន យ៉ាង សូមដកស្រង់ "ត្រូវកម្ទេច" និងទី២ ទាក់ទងទៅនឹងមនុស្សពីរនាក់ ដែល ស៊ីន យ៉ាង បានកំណត់ថា សូមដកស្រង់ "ត្រូវបានចាប់ខ្លួន" បញ្ចប់ការដកស្រង់។

[១១:០៥:១០]

ដោយសារឯកសារនេះ មានតែជាឯកសារថតចម្លង ដូច្នេះយើងមិនអាចបញ្ជាក់ថាតើចំណារសរសេរដោយដៃនូវជាប៊ិកក្រហមនេះ គឺជា -- ដូចដែលសាក្សី ពេជ្រ ជឹម បានបញ្ជាក់កហើយ អាចមានលក្ខណៈខុសគ្នា អំពី -- នៅក្នុងចំណារទាំងអស់នេះ។ ហើយវាក៏មិនច្បាស់ផងដែរ ថាតើអ្នកណាជាអ្នកសរសេរដោយដៃនេះ? ហើយតើចំណារនេះសរសេរនៅពេលណា នៅលើឯកសារនេះ?

ហើយជាចុងក្រោយ លោកប្រធានឯកសារនេះ គឺជាឯកសារមួយក្នុងចំណោមឯកសារជាច្រើនដែលបានចងក្រងនេះ។ ហេតុដូច្នេះ ការជំទាស់របស់យើងខ្ញុំ គឺវាពាក់ព័ន្ធទៅនឹង១ខ្សែចង្វាក់នៃការទុកដាក់ឯកសារ ក៏ដូចជា ៀភនីយហេតុនៃឯកសារនេះផងដែរ។

ចំណុចចុងក្រោយគឺការរាយការណ៍ទៅថ្នាក់ស្រុក និង -- ការរាយការណ៍ទៅថ្នាក់ស្រុកនិងពីភូមិភាគមកភ្នំពេញ។ ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងផ្នែកនេះហើយ ទី១ យើងខ្ញុំសូមលើកឡើងនូវឯកសារពីដំបូង គឺឯកសារ E3/2109 និង E3/4085 ដែលសហព្រះរាជអាជ្ញារៀបរាប់ថាជារបាយការណ៍ប្រចាំខែមកពីគុកក្រាំងតាចាន់។ ការជំទាស់របស់យើងខ្ញុំ គឺឯកសារទាំងអស់នេះមិនបានបញ្ជាក់ឲ្យឃើញថាវាជាការរាយការណ៍មកពីគុកក្រាំងតាចាន់នោះទេ ឈ្មោះពាក្យថា"ក្រាំងតាចាន់" ឬ"ក៏មជ្ឈមណ្ឌលអប់រំកែប្រែស្រុក១០៥" ក៏មិនបានលើកយកមកនិយាយនៅក្នុងឯកសារភាសានេះដែរ។ ហើយជាក់ជាងនេះទៅទៀត គឺឯកសារ E3/2109 រួមបញ្ចូលនូវព័ត៌មាន ឧទាហរណ៍ ការចែក -- ផ្ដល់ស្រូវទៅឲ្យស្រុកសំរោង និងការផ្ដល់ស្រូវនិងដំឡូង បាទទៅស្រុកសំរោង។ ឯកសារនេះ គឺមិនបានបង្ហាញឲ្យឃើញច្បាស់លាស់នៅឡើយទេ ហើយឯកសារចុងក្រោយដែលពាក់ព័ន្ធទៅនឹងការបង្ហាញរបស់សហព្រះរាជអាជ្ញា គឺឯកសារ E3/853 គឺជារបាយការណ៍ពីភូមិភាគនីរតី ជូនអង្គការ -- ប្រហែលជា

ជូនទៅមជ្ឈិម ចុះថ្ងៃទី៣ មិថុនា ១៩៧៧។

[១១:០៧:៤៨]

ការជំទាស់តវ៉ារបស់យើងខ្ញុំទៅលើឯកសារនេះលោកប្រធាន គឺថា សហព្រះរាជអាជ្ញា ហាក់បីដូចបានបង្ហាញនូវព័ត៌មានដែលបានជ្រើសរើស ហើយចំណុចលម្អិតវិញ គឺថាវាទៅជាចំណុចលម្អិតគឺខកខានមិនបានយកមកដាក់បញ្ចូលទេ។ ហើយចំណុចទាំងអស់នេះ ខ្ញុំសូមលើកឡើង ទី១ របាយការណ៍ហ្នឹងនិយាយថារបាយការណ៍លេខ១០ ដែលបញ្ជាក់ន័យថាជារបាយការណ៍មួយដល់ប្រាំបួន។ បញ្ជាក់ថាត្រូវតែមានរបាយការណ៍ពីមួយដល់ប្រាំបួនបានទើបមានរបាយការណ៍លេខ១០។ ដូច្នេះ តើមួយដល់ប្រាំបួននៅឯណា? ហើយរបាយការណ៍នេះហាក់បីដូចរៀបរាប់ពីស្ថានភាពការពារទូទៅនៅក្នុងភូមិភាគសកម្មភាពខ្មាំងផ្នែកនៃការការពារនៃរបាយការណ៍នេះ វាមានប្រហែលជាមួយភាគបីនៃកម្រាស់ឯកសារនេះទាំងមូលតែម្តង។ ហើយវាហាក់ដូចជាមិនបានឆ្លុះបញ្ចាំងឲ្យឃើញនូវភាពភ័យខ្លាច ពាក់ព័ន្ធទៅនឹងព្រឹត្តការណ៍ដែលបានលើកឡើងទាក់ទងទៅនឹងការវាយប្រហារពីសំណាក់កម្លាំងរបស់ ច័ន្ទ រង្សី ចលនាការ១ចល័តទ័ពចូលមកក្នុងប្រទេសកម្ពុជាពីសំណាក់ប្រទេសវៀតណាម ការជីកត្រង់សេ ជាដើម។ល។ សូមដកស្រង់៖ “ខ្មាំងបានធ្វើសកម្មភាពរបស់ខ្លួនវា ដោយជ្រៀតចូលមកក្នុងជួរកុមារ ចូលមកដោយដុតក្មេង១នៅរស់” គឺឯកសារយោង 00185243, ខ្មែរ 00052825, បារាំង 00290267។

[១១:០៩:៣៦]

ជាចុងក្រោយនៅលើឯកសារនេះ របាយការណ៍ពីភូមិភាគនិរតីជូនទៅមជ្ឈិម គឺស្នើសុំ -- សូមដកស្រង់៖ “វិធានការសម្រាប់អនាគត៖ គ្រប់កម្រិតទាំងអស់ត្រូវតែមានការយកចិត្តប្រុងប្រយ័ត្ន ហើយនិងសកម្មភាពល្បិចកលរបស់ខ្មាំង ត្រូវតែតាមដាន២៤ម៉ោង”។ នេះគឺជារបាយការណ៍ពីភូមិភាគមកថ្នាក់មជ្ឈិម។ ហើយវាពិបាកណាស់ដែលអាចនឹងនាំឲ្យមានសេចក្តីសន្និដ្ឋានមក មុននឹងឈានទៅដល់ការធ្វើសេចក្តីសន្និដ្ឋានទៅលើករណីរបស់បុគ្គលណាម្នាក់។ នេះគឺជាសេចក្តីបញ្ចប់ការជំទាស់តវ៉ារបស់យើងខ្ញុំទៅលើឯកសារដែលសហព្រះរាជអាជ្ញាបង្ហាញឡើងពាក់ព័ន្ធទៅនឹងស្រុកត្រាំកក់ និងក្រាំងតាចាន់។

មួយទៀតគឺពាក់ព័ន្ធទៅនឹងការបង្ហាញរបស់សហមេធាវីនាំមុខ។ នៅក្នុងដំណាក់កាលនេះក៏យើងមានពេលវេលាកម្រិតផងដែរ គឺថាសេចក្តីជំទាស់របស់យើងខ្ញុំសង្ខេបទេ ក៏ប៉ុន្តែខ្ញុំកត់សម្គាល់ថាយើងខ្ញុំមានផែនការនឹងផ្តល់ការអត្ថាធិប្បាយលម្អិតនៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់យើងខ្ញុំ នៅឬ -- និងនៅក្នុងឱកាសដែលសមស្រប។ សរុបមកគឺថាសហមេធាវី -- សហមេធាវីនាំមុខ

បានដកស្រង់ចេញពីក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនបានចូលខ្លួនមកចំពោះមុខអង្គជំនុំជម្រះនោះទេ។ ហើយជាពិសេសវាពាក់ព័ន្ធទៅនឹងសក្ខីកម្ម ពាក់ព័ន្ធទៅនឹងអំពើ ហើយនិងឥរិយាបថរបស់ជនជាប់ចោទ។

[១១:១១:២០]

ឥឡូវនេះពាក់ព័ន្ធទៅនឹងសេចក្តីសង្ខេប កាលពីលើកឡើងកាលពីថ្ងៃចន្ទ គឺវាមានឯកសារសំខាន់ៗ គេហៅថាឯកសារភស្តុតាងសំខាន់ៗនៅក្នុងសំណុំរឿង ដែលមិនត្រូវបានលើកយកបង្ហាញឲ្យឃើញច្បាស់លាស់នៅក្នុងតុលាការទេ។ ដូច្នេះ យើងខ្ញុំជឿជាក់ថា ថាគោលបំណងរបស់យើងខ្ញុំដែលត្រូវផ្តោតទៅលើឯកសារនេះ ជាជាងការយកចម្លើយរបស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីដែលអាចមកផ្តល់សក្ខីកម្មនៅទីនេះបាន ប៉ុន្តែមិនបានមកនោះ ហើយជាពិសេសសវនាការពាក់ព័ន្ធទៅនឹងឯកសារនៅក្នុងសហការនោះតែម្តង ដែលអាចបង្ហាញឲ្យនូវឃើញអង្គហេតុ ក៏ដូចជាទៅបង្ហាញឲ្យឃើញនូវសក្ខីកម្មនិងការចងចាំរបស់សាក្សីដែលវាអាចឲ្យស៊ីចង្វាក់គ្នា។ កាលពីថ្ងៃចន្ទសហមេធាវីនាំមុខបានយោងទៅលើអ្វីដែលលើកឡើងកាលពីថ្ងៃចន្ទហ្នឹង គឺអ្នកទាំងនោះគឺមិនបានមកបង្ហាញខ្លួន ដើមបណ្តឹងរដ្ឋប្បវេណីទាំងប្រាំមួយមិនបានខ្លួនមកបង្ហាញនៅក្នុងសវនាការទេ។ ដូច្នេះក្នុងបរិបទនេះ ការគ្រាន់តែអានចេញពីកំណត់ត្រាមួយពាក្យម្តងៗនោះ យើងខ្ញុំជឿថាគឺអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីហ្នឹងនេះ គឺហាក់បីដូចជាគឺថាចាត់ទុកថា ចម្លើយរបស់ពួកគាត់ ពាក្យពេចន៍របស់ពួកគាត់ ស្មើនឹងការផ្តល់សក្ខីកម្មដែលរារាំងមិនឲ្យលោក នួន ជា ក៏ដូចជាភាគីដទៃទៀត អង្គជំនុំជម្រះ គឺថាចោទជាសំណួរដើម្បីចង់ដឹងអំពីៗភស្តុតាងជាក់លាក់ស្តែងរបស់អ្នកទាំងអស់នេះ។

[១១:១៣:០៧]

ហើយជាចុងក្រោយ គឺយើងមានការកត់ត្រាទូទៅមួយ ដែលថាច្បាស់ហើយវាការចាំបាច់ណាស់ យើងខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះបញ្ជាក់ សួរបញ្ជាក់ឡើងវិញពាក់ព័ន្ធទៅនឹងសវនាការស្តីអំពីការបង្ហាញឯកសារនេះ។ កូនក្តីរបស់ខ្ញុំលោក នួន ជា គឺថាខឹងសម្បាខ្លាំងណាស់ចំពោះការប្រព្រឹត្តឡើងរបស់អង្គជំនុំជម្រះមកលើក្រុមមេធាវីការពារក្តី ខៀវ សំផន កាលពីថ្ងៃអង្គារ ដែលថាតាមការបង្ហាញឯកសារនេះ គឺថាមិនអាចឲ្យយើងយល់ប្រកបទៅដល់ហេតុផលបានទេ។ យើងខ្ញុំសង្ឃឹមថានឹងមានការសួរបញ្ជាក់ឯកសារនេះបានច្បាស់លាស់មុននឹងចូលទៅដល់សវនាការស្តីអំពីការបង្ហាញឯកសារនៅវគ្គបន្ទាប់។

បាទ សូមអរគុណច្រើនលោកប្រធាន ខ្ញុំអស់ហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ តទៅនេះខ្ញុំសូមជម្រាបសួរអង្គជំនុំជម្រះ ហើយនិងភាគីទាំងអស់។ ដោយឃើញពេលវេលានៅសល់ប្រហែលជាជិត២០នាទីដែរ ប៉ុន្តែបើសិនជាលើសពេលសូមឲ្យលោកប្រធានអនុញ្ញាតបន្តិចទៅ ហើយយើងអាចបញ្ចប់នៅពេលព្រឹកនេះតែម្តង។

[១១:១៤:៣១]

ខ្ញុំសូមអនុញ្ញាតធ្វើការឆ្លើយតបទៅនឹងការដាក់បង្ហាញភស្តុតាងរបស់តំណាងសហព្រះរាជអាជ្ញាក៏ដូចជាដើមបណ្តឹង មេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ ជាដំបូង -- ខាងភាគីអន្តរជាតិថាអត់បានបកប្រែទៅលើសម្តីដែលខ្ញុំនិយាយអម្បាញ់មិញ។ អម្បាញ់មិញខ្ញុំបានជម្រាបថា ក្នុងករណីដែលអាចបញ្ចប់ក្នុងពេលដ៏ឆាប់ខាងមុខនេះ នឹងស្នើសុំអង្គជំនុំជម្រះបន្តថែមពេលវេលា ដើម្បីបញ្ចប់ពេលព្រឹកនេះ។

ទាក់ទងទៅនឹងឯកសារ E3/1593 ដែលជាឯកសាររបស់ លោក ប៉ែន យៀវនិន ខ្ញុំបានឮលោកមេធាវី កូប៉េ បានបកស្រាយឆ្លើយតបទៅនឹងចំណុចសំខាន់នៃបញ្ហានេះហើយ គឺថាលោក ប៉ែន យៀវនិន មិនបានមកឆ្លើយបំភ្លឺនៅចំពោះមុខអង្គជំនុំជម្រះទេ ហើយក៏គ្មានផែនការណាមួយ នឹងអញ្ជើញលោកឲ្យមកឆ្លើយបំភ្លឺនៅក្នុងពេលអនាគតនេះទៀតដែរ។ ដូច្នេះ ការសំអាងទៅលើឯកសារដែលលើកឡើងដោយ លោក ប៉ែន យៀវនិន នោះ គឺជាបញ្ហាដែលធ្វើឲ្យមានតម្លៃនៃភស្តុតាងទាបបំផុត ហើយចំណុចនេះអង្គជំនុំជម្រះក៏បានចេញនូវសេចក្តីណែនាំបញ្ជាក់នៅ កាលពីសំណុំរឿង០០២/០១ រួចហើយទាក់ទងទៅនឹងតម្លៃនៃភស្តុតាងរបស់លោក ប៉ែន យៀវនិន នេះ។

[១១:១៦:២១]

តែទោះយ៉ាងណាក៏ដោយ ខ្ញុំបានពិនិត្យឃើញថានៅក្នុងសំណេររបស់លោក ប៉ែរ យៀវនិន នោះក៏មានចំណុចដែលបញ្ជាក់នូវភាពមិនប្រក្រតីដែលលោកបានលើកអំពីភស្តុតាងផ្ទុយគ្នាក្នុងការទទួលបាននូវម្ហូបអាហារនៅក្នុងស្រុកត្រាំកក់ ដែលតំណាងសហព្រះរាជអាជ្ញាបានលើកនៅក្នុងឯកសារ E3/1593 ដែលមានលេខ ERN ជាភាសាខ្មែរ 00678585។ ហើយចំណុចនេះវាជាការបង្ហាញមួយថាមានសាក្សីបញ្ជាក់អំពីថាម្ហូបអាហារនៅស្រុកត្រាំកក់នោះ មិនមានអ្វីជាចំណោទទេ ហើយដូច្នេះវាមានការចំណុច

ខ្មែងគ្នា ដែលតំណាងសហព្រះរាជអាជ្ញាមិនបានអានដល់កន្លែងនោះ។ ទាក់ទងទៅនឹងស្បៀងអាហារនេះដែរ ឯកសារ E3/760 ដែលជាឯកសារទង់បដិវត្ត -- សូមទោស E3/139 ដែលជាទង់បដិវត្តលេខ១១ ខែវិច្ឆិកា ឆ្នាំ៧៦ ដែលមានលេខERN ជាភាសាខ្មែរ 006495 -- អ៎! សូមទោស 00064965 ដល់66, ភាសាអង់គ្លេស 00455284, ភាសាបារាំង 00491919។ ខ្ញុំបាទសូមអានជូន ដកស្រង់៖ "តើនិយមន័យអនុវត្តជាក់ស្តែងយ៉ាងម៉េច? ទី១ របបហូប១៣ចាំង។ យើងសម្រេចបានគន្លឹះ ឆ្នាំ១៩៧៦ ដូច្នេះយើងអនុវត្តផែនការរបបហូប១៣ចាំង របស់ប្រជាជននៅទូទាំងប្រទេសក្នុងឆ្នាំ១៩៧៧ បានជាទូទៅ។ បក្សកំណត់ថា សម្រេចឲ្យបានរបប១៣ចាំង ១០០ភាគរយ មិនឲ្យចុះមក១២ចាំង ឬ១០ចាំងទេ"។ ដូចគ្នានេះដែរ នៅក្នុងទង់បដិវត្តន៍លេខពិសេស ខែធ្នូ មករា ឆ្នាំ១៩៧៦ – ៧៥-៧៦ ដែលមានលេខ E3/25, ERNជាភាសាខ្មែរ 00063054, ភាសាអង់គ្លេស 00491436, ភាសាបារាំង 00--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១១:២១:១៨]

**លោក ខេល លីសាក់៖**

ខ្ញុំគ្រាន់តែសុំកត់សម្គាល់សម្រាប់ប្រតិចារឹកថា ឯកសារទាំងពីរចុងក្រោយនេះ មិនពាក់ព័ន្ធទៅនឹងឯកសារដែលខ្ញុំបានបង្ហាញទេ។ នេះគឺជាឯកសារដែលមាននៅលើបញ្ជីរបស់មេធាវី ខៀវ សំផន ដែលចង់បង្ហាញ។ ខ្ញុំមិនជំទាស់ទៅនឹងការឆក់យកឱកាសដើម្បីបង្ហាញឯកសារនេះ ពីសំណាក់ក្រុមមេធាវីការពារក្តី ខៀវ សំផន ទេ គ្រាន់តែបញ្ជាក់ថា គាត់អានចេញពីអ្វីដែលទាំងពីរនេះគឺថាមិនពាក់ព័ន្ធទៅនឹងបទបង្ហាញឯកសាររបស់យើងខ្ញុំទេ។

**លោក គង់ សំអុន៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតឆ្លើយទៅនឹងសំណួរនេះ។ ដោយហេតុថា លក្ខខណ្ឌនៃការទទួលខុសត្រូវរបស់លោក ខៀវ សំផន មានភាពខុសគ្នាទៅនឹងជនជាប់ចោទដទៃទៀតនៅក្នុងតុលាការនេះ ហើយបញ្ហានេះដូចលោក ខៀវ សំផន គាត់បានបញ្ជាក់ពីជំហររបស់គាត់ដែលគាត់គាំទ្រទៅលើនយោ-បាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយចំណុចនេះហើយដែលធ្វើឲ្យយើងយល់ថា បើសិនជាយើងមិនលើកពីបញ្ហាគោលនយោបាយនោះទេ ដូច្នេះវាអត់មានអ្វីដែលយើងត្រូវបញ្ជាក់ពីភាពពាក់ព័ន្ធរបស់លោក ខៀវ សំផន ទៅនឹងថ្នាក់មូលដ្ឋាននោះទេ។ ហើយកន្លងមកតំណាង

សហព្រះរាជអាជ្ញាក៏មិនបានបង្ហាញភស្តុតាងដែលភ្ជាប់ទំនាក់ទំនងរវាងលោក ខៀវ សំផន ទៅនឹងថ្នាក់មូលដ្ឋាននេះដែរ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតឱ្យអង្គជំនុំជម្រះមេត្តាអនុញ្ញាតឱ្យយើងខ្ញុំ អាចបង្ហាញឯកសារជាលក្ខណៈគោលនយោបាយបែបនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតអញ្ជើញបន្តចុះ។ សហព្រះរាជអាជ្ញារងអន្តរជាតិ គ្រាន់តែធ្វើការកត់សម្គាល់ប៉ុណ្ណោះ មិនមានការជំទាស់អ្វីទេ។

[១១:២៣:១៨]

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ ខ្ញុំសូមដកស្រង់ទស្សនាវដ្ដីបដិវត្តន៍លេខពិសេស ខែធ្នូ-មករា ឆ្នាំ១៩៧៥-៧៦។ ដកស្រង់៖ “សារៈសំខាន់នៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមមានទិសដៅកសាងប្រទេសបានល្អ និងដោះស្រាយជីវភាពប្រជាជនឱ្យបានឆាប់រហ័ស” សូមបញ្ចប់ការដកស្រង់។ ចំណុចទី២ ទាក់ទងទៅនឹងការងារសហករណ៍។ តំណាងសហព្រះរាជអាជ្ញាបានបង្ហាញឯកសារទាក់ទងទៅនឹងការបែងចែកប្រជាពលរដ្ឋជាបីប្រភេទ ដែលយើងមានអ្នកមូលដ្ឋាន សមាជិកត្រៀម ឬបម្រុង និងសមាជិកបញ្ញើ។ ទាក់ទងបញ្ហានេះ យើងមិនមានឃើញជាលក្ខណៈនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា បង្ហាញពីការបែងចែកប្រជាជនក្នុងគោលបំណងដើម្បីរើសអើងក្នុងការងារ ឬក្នុងរបបអាហារនោះទេ។ ជាក់ស្ដែងឯកសារ E3/742 បានបញ្ជាក់អំពីការបែងចែកកម្លាំងដូចលើកឡើងដោយសហព្រះរាជអាជ្ញានោះ គឺដើម្បីឱ្យមានការសហការគ្នាល្អ ការសាមគ្គីគ្នាល្អ ក្នុងការប្រកបការងារទៅវិញនោះទេ។

[១១:២៦:១៤]

ទាក់ទងនឹងចំណុចការសម្រេចរបស់ថ្នាក់ដឹកនាំក្នុងការវាយយកកម្ពុជាក្រោមមកវិញ ដែលតំណាងសហព្រះរាជអាជ្ញាបានលើកដើម្បីបង្ហាញអំពីទំនាស់ប្រដាប់អាវុធ ដែលមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយជាពិសេសគឺទាក់ទងទៅនឹងតំបន់ត្រាំកក់នេះ។ ខ្ញុំបាទយល់ឃើញថាការលើកឡើងរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងភស្តុតាងដែលជាសម្ដីរបស់ តាសាន ជាលេខាស្រុកម្នាក់ដែលបានចូលរួមប្រជុំជាមួយនឹងគណៈឃុំ ដើម្បីពន្យល់អំពីបំណងរបស់អង្គការក្នុងការវាយដណ្ដើមយកកម្ពុជាប្រជាធិបតេយ្យ គឺមិនស្ថិតចូលនៅក្នុងការពិភាក្សាដេញដោលក្នុងពេលនេះទេ។

អង្គជំនុំជម្រះបានចេញនូវសេចក្ដីសម្រេចមួយដែលមានលេខ E315 ពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០១៤ បានបំបែកផ្នែកតូចៗទៀតស្ថិតនៅក្នុងចំណុចនេះ ដែលស្ថិតនៅក្នុងចំណុច(ច) លក្ខណៈនៃជម្លោះប្រដាប់អាវុធ។ ដូច្នេះ ខ្ញុំបាទសុំមិនធ្វើការឆ្លើយតបទៅនឹងភស្តុតាងដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាទាក់ទងទៅនឹងការវាយយកកម្ពុជាក្រោមនេះទេ។

ដូចគ្នានេះដែរនៅក្នុងការប្រព្រឹត្តលើជនជាតិវៀតណាមនិងខ្មែរក្រោម ដែលសហព្រះរាជអាជ្ញាបានលើកឯកសារជាច្រើនទាក់ទងនឹងចំណុចនេះ ក៏ប៉ុន្តែក្នុងពេលបច្ចុប្បន្ននេះ យើងមិនធ្វើការពិភាក្សាទៅលើការប្រព្រឹត្តលើក្រុមគោលដៅជាក់លាក់នោះទេ។ ហេតុដូច្នេះ ខ្ញុំបាទមិនធ្វើការឆ្លើយតបទាក់ទងនឹងចំណុចនេះដែរ។

[១១:២៩:២៤]

បាទ ទាក់ទងទៅនឹងការបោសសម្អាតទាហាន និងមន្ត្រីរដ្ឋការលន់ នល់។ តំណាងសហព្រះរាជអាជ្ញាបានលើកឯកសារ E3/2120 របស់លោក អៀ ម៉េងទ្រី យើងខ្ញុំបានពិនិត្យទៅលើចំណុចទាំងអស់ដែលតំណាងសហព្រះរាជអាជ្ញាបានយោងមានប្រាំមួយចំណុច ក៏ប៉ុន្តែមានពីរចំណុច និយាយពីលក្ខណៈទូទៅ និងបួនចំណុចនិយាយពីករណីជាក់លាក់។ ប៉ុន្តែក្នុងនោះ គ្មានចំណុចណាមួយបង្ហាញពីទំនាក់ទំនងរវាងស្រុកត្រាំកក់ទេ គឺមានតែចំណុចមួយដែលមិនមានភាពច្បាស់លាស់ទៀត ហើយក្រៅពីនោះ គឺមាននិយាយអំពីស្រុកព្រៃកប្បាស និងស្រុកបាទី ដែលមានឈ្មោះ ឈិន និងឈ្មោះ ធុយ ដែលជាអ្នកផ្ដល់ព័ត៌មានឲ្យ អៀង ម៉េងទ្រី នោះ។ ដូច្នេះ ការដកស្រង់ដែលតំណាងសហព្រះរាជអាជ្ញាយល់ថាវាជាប់ពាក់ព័ន្ធនឹងស្រុកត្រាំកក់នេះ គឺមិនមែនជាការពិតទេ ដោយសារក្នុងអត្ថបទ គឺនិយាយសំដៅទៅលើស្រុកបាទី និងស្រុកព្រៃកប្បាស គឺជាទឹកដីដោយឡែក។

[១១:៣១:៥៧]

បាទ ចំណុចចុងក្រោយមួយទៀត ទាក់ទងទៅនឹងភស្តុតាងរបស់តំណាងសហព្រះរាជអាជ្ញាដែលបានលើកអំពីបទល្មើសផ្សេងៗ ជាពិសេសទាក់ទងទៅនឹងការលួចហូប ការលួចដូង ការដេញទាចូលស្រែ ហើយត្រូវទទួលទោស។ ចំណុចនេះ ខ្ញុំបានយល់ស្របទៅនឹងការលើកឡើងរបស់មេធាវី កូប៉េ ដែលបានបញ្ជាក់អំពីសក្ខីកម្មរបស់លោក ឈិន។ បាទ គឺសក្ខីកម្មរបស់ តាឈិន ដែលជាគណៈស្រុក ហើយនិងមានកម្មាភិបាលមួយចំនួនទៀត អតីតកម្មាភិបាលមួយចំនួនទៀតថា បទល្មើសតូចតាចបែបនេះគេមិនបញ្ជូនទៅក្រាំងតាចាន់ទេ។ វាអាចត្រូវទទួលការអប់រំ ណែនាំ ហើយត្រូវឲ្យដោះលែងរួចខ្លួន

វិញ។ ដូច្នេះ ចំណុចនេះវាមានភស្តុតាងផ្ទុយគ្នាដែលអង្គជំនុំជម្រះអាចលើកមកពិចារណាបាន។

ខ្ញុំសូមឆ្លើយតបទៅនឹងមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី។ មេធាវីនាំមុខបានលើកទម្រង់ព័ត៌-មានប្រាំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានលេខ E3/6143, E3/6457, E3/4988, E3/6222, E3/5069 និងមានកំណត់ហេតុស្តាប់ចម្លើយនៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេតដែលមានលេខ E3/5519។

មុននេះ លោកមេធាវី កូប៉េ ក៏បានលើកពីចំណុចនេះហើយដែរ ដោយហេតុថាអ្នកទាំងអស់នេះមិនបានមកបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះទេ ហើយក៏គ្មានគម្រោងថានឹងហៅក្នុងពេលអនាគតដែរ។ ដូច្នេះការលើកសក្ខីកម្មមួយដើម្បីយកមកប្រើប្រាស់ក្នុងរឿងព្រហ្មទណ្ឌបែបនេះ មិនមានតម្លៃជាភស្តុតាងសម្រាប់ឱ្យអង្គជំនុំជម្រះជឿបានទេ។

[១១:៣៥:៤៧]

ជាក់ស្តែងមេធាវី ម៉ារី ហ្គីរ៉ូដ៍ បានលើកថាខ្លួនជាអ្នកនាំពាក្យរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយដែលត្រូវឡើងមកបង្ហាញចំពោះមុខអង្គជំនុំជម្រះ កាល -- គឺជាការបង្ហាញនៅថ្ងៃទី២៧ ខែ៤ កន្លងទៅនេះ នៅម៉ោងប្រហែល១៤:២៣:២៣។ ចំណុចនេះ សម្រាប់អង្គជំនុំជម្រះ ខ្ញុំយល់ថាមិនពិបាកយល់ទេពីព្រោះដើមបណ្តឹងរដ្ឋប្បវេណី -- មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនជាអ្នកនាំពាក្យរបស់កូនក្តីខ្លួនក្នុងការផ្តល់សក្ខីកម្មបានទេ ជាពិសេសគឺទាក់ទងទៅនឹងរឿងព្រហ្មទណ្ឌ ក៏ប៉ុន្តែមេធាវីដើមបណ្តឹងរដ្ឋប្បវេណី អាចជាអ្នកនាំពាក្យក្នុងករណីដែលទាក់ទងទៅនឹងសំណង។ ម៉្យាងទៀត មេធាវីដើមបណ្តឹងរដ្ឋប្បវេណីខ្លួនឯងក៏ធ្លាប់ទទួលស្គាល់ថាមានចំណុចជាច្រើនដែលខុសគ្នានៅក្នុងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីធៀបជាមួយនឹងទម្រង់ព័ត៌មាន ដែលបានដាក់ជូនអង្គជំនុំជម្រះក្នុងពេលកន្លងមក។ ដូចមាននៅក្នុងឯកសារ E1/288.1 ជាកំណត់ហេតុសវនាការ នៅម៉ោង០៩:៤០:៥៩។

[១១:៣៨:១៩]

យោងលើចំណុចដូចខ្ញុំបានលើកជូនអង្គជំនុំជម្រះនៅពេលនេះ ការផ្តល់សក្ខីកម្ម ការផ្តល់បង្ហាញភស្តុតាងរបស់មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ចំពោះទម្រង់ព័ត៌មានរបស់កូនក្តីខ្លួនខាងលើ ដែលមិនបានចូលរួមនៅក្នុងសវនាការនៅពេលនោះ វាមិនបានផ្តល់ឱកាសឱ្យភាគីក្នុងការសួរដេញដោលដើម្បីស្វែងរកការពិតបានឡើយ។ ហេតុនេះភស្តុតាងបែបនេះ វាធ្វើឱ្យតម្លៃនៃភស្តុតានេះមិនមានតម្លៃល្អទេ។ បាទ សូមអរគុណលោកប្រធាន។

[១១:៣៩:១៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះធ្វើសវនាការស្តាប់នូវសារណាតបរបស់ភាគីលើការដាក់ បង្ហាញឯកសារគន្លឹះពាក់ព័ន្ធជាមួយនឹងអង្គហេតុសហករណ៍ត្រាំកក់និងក្រាំងតាចាន់ ដល់ពេលនេះឃើញថាដល់ទីបញ្ចប់ហើយៗបានចប់មុនពេលវេលាដែលអង្គជំនុំជម្រះបានរំពឹងទុក។

ដូច្នេះ សវនាការនៅថ្ងៃនេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការត្រឹមនេះ។ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី០៤ ខែឧសភា ឆ្នាំ២០១៥ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃចន្ទ ដើមសប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-979 តាមរយៈប្រព័ន្ធសោតទស្សន៍ បាទសូមភាគីជ្រាប និងអញ្ជើញចូលរួមតាមវេលាបានកំណត់នេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួន ខៀវ សំផន និង នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ត្រឡប់មកចូលរួមសវនាការវិញ នៅថ្ងៃច័ន្ទ ទី០៤ ខែឧសភា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១១:៤០ នាទី)*